ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា



# របាយការណ៍ស្តីពី
# លទ្ធផលការងាររបស់វិទ្យាស្ថាន
# ស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
# ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល
# អាណត្តិទី៥ ២០១៤-២០១៧




ស្រាវជ្រាវដើម្បីការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាពនៅកម្ពុជា

Cambodian Agricultural Research and Development Institute

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (វិទ្យាស្ថានកាឌី) ជាគ្រឹះស្ថានសាធារណរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានក្រុមប្រឹក្សាភិបាលដឹកនាំសម្រាប់អាណត្តិបីឆ្នាំ។ ឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលអាណត្តិទី៥ក្នុងការជំរុញវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រគល់ភារកិច្ចឲ្យវិទ្យាស្ថានកាឌី ស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាសំដៅបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មដំណាំកសិកម្ម រួមចំណែកធានាសន្តិសុខនិងសុវត្ថិភាពស្បៀង តម្រូវការទីផ្សារ និងអាហារូបត្ថម្ភ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

របាយការណ៍ស្តីពី **លទ្ធផលការងាររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥** នេះ បង្ហាញនូវការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាលក្នុងការគិតគូរក្នុងការបង្កើនថវិកាផ្តោតទៅលើសកម្មភាពស្រាវជ្រាវនិងការផ្សព្វផ្សាយ និងចូលរួមសកម្មភាព ផ្តល់នូវអនុសាសន៍និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំវិទ្យាស្ថានកាឌី ឲ្យដឹកនាំនិងប្រតិបត្តិការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា ស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលអាណត្តិទី៥។

ក្រុមប្រឹក្សាភិបាល សូមកោតសរសើរចំពោះការងារគ្រប់គ្រងនិងលទ្ធផលសំខាន់ៗនៃការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា ដែលវិទ្យាស្ថានកាឌីសម្រេចបានក្នុងអាណត្តិទី៥ គឺជាការបន្តពីអាណត្តិមុនៗកន្លងមក ដូចមានបង្ហាញជាសង្ខេបក្នុងរបាយការណ៍នេះ។ លទ្ធផលទទួលបានទាំងអស់នេះ បញ្ជាក់នូវសាមគ្គីភាពនិងកិច្ចប្រឹងប្រែងរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់រួមទាំងកិច្ចសហប្រតិបត្តិការល្អជាមួយកសិករផ្ទាល់និងអ្នកពាក់ព័ន្ធ ហើយជាពិសេសអ្នកវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ។

ក្រុមប្រឹក្សាភិបាល មានមោទនភាពជាខ្លាំងចំពោះសមិទ្ធផលការងាររបស់ថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់នៃវិទ្យាស្ថានកាឌីដែលទទួលបានកន្លងមកនេះ។ ជាក់ស្តែង អង្ករពូជស្រូវផ្ការំដួល ត្រូវបានចាត់ទុកថា អង្ករមានគុណភាពអង្ករនិងរសជាតិបាយក្រអូបឆ្ងាញ់លេខ១ក្នុងពិភពលោករយៈពេល០៣ឆ្នាំជាប់ៗគ្នា (២០១២-២០១៤) នៅក្នុងវេទិកាប្រកួតប្រជែងពិភពលោក ដែលបានប្រព្រឹត្តទៅនៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០១២ នៅទីក្រុងហុងកុង ប្រទេសចិន ឆ្នាំ២០១៣ និងនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ២០១៤ ដែលរៀបចំឡើងដោយស្ថាប័នបណ្តាញអ្នកជំនួញអង្ករ (Rice Trader) មានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ លោកនាយកវិទ្យាស្ថានកាឌី ត្រូវបានក្រសួងអប់រំ យុវជននិងកីឡាជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រឆ្នើម** សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ទន្ទឹមនឹងនេះក៏ត្រូវបានជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រស្រូវឆ្នើម** និងជា **ឯកអគ្គរាជទូតវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាស្រូវ** តំណាងប្រទេសកម្ពុជាប្រចាំអាស៊ានសម្រាប់ស្នាដៃការងារជាគំរូ ដែលបានចូលរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍន៍និងស្រាវជ្រាវលើដំណាំស្រូវប្រកបដោយនិរន្តរភាពនិងបានផ្តល់នូវផលប្រយោជន៍យ៉ាងសំខាន់ដល់កសិករនិងអ្នកប្រើប្រាស់ ក្នុងខួបលើកទី៥០ របស់អាស៊ាន ដែលបានរៀបចំឡើងដោយអាស៊ាន ក្រសួងកសិកម្មនៃប្រទេសហ្វីលីពីន និងវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) ប្រព្រឹត្តទៅនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ពិសេសទៅទៀតនោះនាពិធីបិទសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧កន្លងមកនេះ ទន្ទឹមនឹងការសរសើរការបញ្ចេញពូជស្រូវ ខា១៦ និងស្នាច់០២ ត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍បញ្ជាក់ថា វិទ្យាស្ថានកាឌីនឹងត្រូវដើរតួកាន់តែសកម្មក្នុងបរិការ ដែលពិភពលោកស្ថិតក្នុងពេលវេលាដ៏លំបាកទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងបានលើកទឹកចិត្តឲ្យមន្ត្រីរាជការនិងអ្នកបច្ចេកទេសវិទ្យាស្ថានកាឌីបន្តស្វែងរកពូជស្រូវថ្មីៗនិងពូជដំណាំផ្សេងទៀតរួមទាំងផ្កាផងដែរ។

Cambodian Agricultural Research and Development Institute

ទន្ទឹមនឹងសមិទ្ធផលទាំងនេះ ក្រុមប្រឹក្សាភិបាលសង្កេតឃើញថា វិទ្យាស្ថានកាឌីត្រូវការការគាំទ្របន្ថែមទៀតទាំងធនធានមនុស្ស ថវិកា និងការលើកទឹកចិត្តជាពិសេស ដើម្បីពង្រឹងសមត្ថភាពប្រតិបត្តិឲ្យកាន់តែមានប្រសិទ្ធភាព រួមទាំងពង្រីកវិសាលភាពស្រាវជ្រាវលើដំណាំកសិកម្មនិងផ្កា ស្របតាមអនុសាសន៍របស់ **សម្តេចតេជោ** និងការផ្សព្វផ្សាយអំពីលទ្ធផលការងារឲ្យបានកាន់តែទូលំទូលាយ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧

ប្រធានក្រុមប្រឹក្សាភិបាល

ហត្ថលេខា

**ហ៊ួត ប៊ុនណារី**

Cambodian Agricultural Research and Development Institute

# ឧបសម្ព័ន្ធ: ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាអាណត្តិទី៥



**ឯកឧត្តម ហ៊ួត ប៊ុនណារី**
**អាណត្តិទី៥**
ប្រធាន-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ



**ឯកឧត្តម ទ្រី មេង**
**អាណត្តិទី៥**
សមាជិក-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ



**បណ្ឌិត អ៊ុក ម៉ាភារា**
**អាណត្តិទី៥**
សមាជិក-នាយកវិទ្យាស្ថានស្រាវជ្រាវនិង
អភិវឌ្ឍន៍កសិកម្មកម្ពុជា



**លោក ខឿ វ៉ូដាឌុល**
**អាណត្តិទី៥**
សមាជិក-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



**លោក សឿង សាំងអេម**
**អាណត្តិទី៥**
សមាជិក-តំណាងទីស្តីការគណៈរដ្ឋមន្រ្តី



**លោក ជា ស៊ីណា**
**អាណត្តិទី៥**
សមាជិក-តំណាងក្រសួងបរិស្ថាន



**លោក សាយ ពុទ្ធា**
**អាណត្តិទី៥**
នីតិសមាជិក-តំណាងមន្រ្តីនិយោជិត
វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា



**លោក យូ សត្ថា**
**អាណត្តិទី៥**
សមាជិក-តំណាងក្រសួងធនធានទឹក
និងឧតុនិយម



**លោក អេង គឹមលី**
**អាណត្តិទី៥**
សមាជិក-តំណាងក្រសួងអប់រំ យុវជន
និងកីឡា



**បណ្ឌិត សេង មុំ**
**អាណត្តិទី៥**
សមាជិក-តំណាងឥស្សរជនមានបទពិសោធន៍
ផ្នែកកសិកម្ម



**លោក ស្រ៊ុន សុខុម**
**អាណត្តិទី៥**
សមាជិក-តំណាងអគ្គនាយកដ្ឋានកសិកម្ម

Cambodian Agricultural Research and Development Institute







សកម្មភាពប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥ (២០១៤-២០១៧)
របស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

Cambodian Agricultural Research and Development Institute

# មាតិកា

**ទំព័រ**


អារម្ភកថា ............ I

ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាអាណត្តិទី៥ ............ III

សកម្មភាពប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥ ............ IV

មាតិកា ............ V

**ក. ផ្នែកស្ថានភាពទូទៅ** ............ ០១

ក.១ តួនាទីរបស់ក្រុមប្រឹក្សាភិបាល ............ ០១

ក.២ តួនាទីរបស់នាយកវិទ្យាស្ថាន ............ ០១

ក.៣ សមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិទី៥ ............ ០២

**ខ. សកម្មភាពគ្រប់គ្រង និងដឹកនាំរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥** ............ ០២

ខ.១ ការងារផែនការសកម្មភាពនិងថវិការបស់វិទ្យាស្ថាន ............ ០២

ខ.២ ការងារមន្ត្រីរាជការរបស់វិទ្យាស្ថាន ............ ០៣

ខ.៣ ការងារលិខិតបទដ្ឋាន ............ ០៣

ខ.៤ ការងារដោះស្រាយនិងសម្របសម្រួល ............ ០៣

ខ.៥ អនុសាសន៍លើការងារ ............ ០៤

**គ. ផ្នែកព្រឹត្តការណ៍សំខាន់ៗនិងការងារគ្រប់គ្រងរបស់វិទ្យាស្ថាន** ............ ០៥

គ.១ ព្រឹត្តការណ៍សំខាន់ៗ និងការចូលរួមរបស់ថ្នាក់ដឹកនាំវិទ្យាស្ថានកាឌី ............ ០៥

គ.២ ស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិក ............ ០៦

គ.៣ ស្ថានភាពហិរញ្ញវត្ថុ ............ ០៧

**ឃ. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨** ............ ០៨

**ង. សមិទ្ធផលនៃការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងផ្ទេរបច្ចេកវិទ្យាក្នុងឆ្នាំ២០១៤-២០១៧** ............ ០៩

ង.១ ការអភិរក្សពូជដំណាំ ............ ០៩

ង.២ ការបញ្ចេញពូជដំណាំថ្មីៗ ............ ០៩

ង.៣ ការងារស្រាវជ្រាវនិងអង្កេតលើដំណាំស្រូវ ............ ១១

ង.៤ ការងារស្រាវជ្រាវលើដំណាំដំឡូងមី ............ ១៦

ង.៥ ការងារស្រាវជ្រាវលើពិពិធកម្មដំណាំលើស្រែទំនាបពឹងទឹកភ្លៀង ............ ១៨

ង.៦ ការងារស្រាវជ្រាវលើដំណាំផ្សេងទៀត ............ ១៨


Cambodian Agricultural Research and Development Institute

ង.៧ ការងារផ្សព្វផ្សាយ ការផ្ទេរបច្ចេកវិទ្យា និងបណ្តុះបណ្តាលធនធានមនុស្ស....................១៩
ង.៨ មន្ទីរពិសោធន៍ ....................២៦
**ច. សន្និដ្ឋាន** ....................២៦
**ឆ. សំណូមពរ** ....................២៧
**ឧបសម្ព័ន្ធ**

Cambodian Agricultural Research and Development Institute

## ក. ផ្នែកស្ថានភាពទូទៅ

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (វិទ្យាស្ថានកាឌី) ដែលមានអក្សរកាត់ វ.ស.អ.ក.ក ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ឋិតក្រោមអាណាព្យាបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្នែកហិរញ្ញវត្ថុ។ វិទ្យាស្ថានកាឌីដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាសភាព១១រូប មកពីស្ថាប័នពាក់ព័ន្ធចំនួន៧ មានអាណត្តិ៣ឆ្នាំ និងមាននាយកប្រតិបត្តិមួយរូប។ វិទ្យាស្ថានកាឌីមានទីតាំងស្ថិតនៅក្នុង ឃុំប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៣ មានស្ថានីយ៍វណបស្រែបច្បាប់មួយមានទីតាំងស្ថិតនៅភូមិស្វាយប៉ាត់ ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ មានផ្ទៃដី៩៥,៦៦៥៣ហិចតា។

ក.១. តួនាទីរបស់ក្រុមប្រឹក្សាភិបាល: ក្រុមប្រឹក្សាភិបាលមានតួនាទីដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើផែនការអភិវឌ្ឍន៍របស់វិទ្យាស្ថានកាឌី
- ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយប្រចាំឆ្នាំរបស់វិទ្យាស្ថានកាឌី
- ពិនិត្យនិងសម្រេចលើរបាយការណ៍គ្រប់គ្រងនិងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅដល់អង្គភាពក្រោមឱវាទ
- កំណត់នូវរបបជ្រើសរើសការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិកវិទ្យាស្ថានកាឌីដោយមិនប៉ះពាល់ដល់បទបញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្ត ចំពោះភ្នាក់ងារមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់វិទ្យាស្ថានកាឌី
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់លើកម្រិតលទ្ធផលសម្រេចបានតាមគោលដៅកំណត់ដោយវិទ្យាស្ថានកាឌី ហើយកំណត់នូវវិធានការកែសម្រួលដើម្បីអនុវត្ត។

ក.២. តួនាទីរបស់នាយកវិទ្យាស្ថានកាឌី: នាយកប្រតិបត្តិមានតួនាទីដូចខាងក្រោម៖

- រៀបចំការងារប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់វិទ្យាស្ថានកាឌី ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច
- ធ្វើរបាយការណ៍ប្រចាំឆ្នាំលើរាល់សកម្មភាព ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ

Cambodian Agricultural Research and Development Institute

- បំពេញរាល់មុខដំណែងរបស់វិទ្យាស្ថានកាឌី ក្នុងកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ជាផ្ទៃក្នុង។

ក.៣. សមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិទី៥

ក្រុមប្រឹក្សាភិបាលអាណត្តិទី៥ របស់វិទ្យាស្ថានកាឌីត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៥៣២អនក្រ.តត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ដែលមានសមាសភាពចំនួន១១រូបមកពីស្ថាប័ននិងអង្គភាពពាក់ព័ន្ធដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម ហ៊ួត ប៊ុនណារី តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | ជាប្រធាន |
| ២. ឯកឧត្តម ទ្រី មេង | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៣. លោក សឿង សាំងអេម | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤. លោក វង្ស វ៉ូដាវុឌ្ឍ | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥. លោក ជា ស៊ីណា | តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ៦. លោក អេង គឹមលី | តំណាងក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ៧. លោក យូ សត្ថា | តំណាងក្រសួងធនធានទឹកនិងឧត្តុនិយម | ជាសមាជិក |
| ៨. លោក ស្រ៊ុន សុខុម | តំណាងអគ្គនាយកដ្ឋានកសិកម្ម | ជាសមាជិក |
| ៩. លោក អ៊ុក ម៉ាការា | នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ជាសមាជិក |
| ១០. លោកស្រី សេង មុំ | ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ផ្នែកកសិកម្ម | ជាសមាជិក |
| ១១. លោក សាយ ពុទ្ធា | តំណាងមន្ត្រីនិយោជិតវិទ្យាស្ថានកាឌី | នីតិសមាជិក |

## ខ. ផ្នែកសកម្មភាពគ្រប់គ្រងនិងដឹកនាំរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៥

ក្នុងអាណត្តិទី៥នេះ ក្រុមប្រឹក្សាភិបាលបានធ្វើការប្រជុំពិភាក្សានិងអនុម័តចំនួន០៩លើក លើរបៀបវារៈជាច្រើន ដោយសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**ខ.១. ការងារផែនការសកម្មភាពនិងថវិការបស់វិទ្យាស្ថានកាឌី៖** ក្រុមប្រឹក្សាភិបាលបានធ្វើការត្រួតពិនិត្យនិងអនុម័តលើផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនីមួយៗ (សូមមើលតារាង២ ទំព័រ៧)។ ប្រការសំខាន់បំផុតនោះគឺក្រុមប្រឹក្សាភិបាលបានធ្វើការយ៉ាងសកម្មក្នុងការស្នើសុំបង្កើនថវិកាសម្រាប់ការងារប្រតិបត្តិរបស់វិទ្យាស្ថានកាឌី ដែលជាអង្គភាពស្រាវជ្រាវដំណាំកសិកម្មតែមួយគត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារបស់រាជរដ្ឋាភិបាលរហូតទទួលបានការឯកភាពបង្កើនថវិកាសម្រាប់ការងាររដ្ឋបាលនិងស្រាវជ្រាវជាបន្តបន្ទាប់ ដូចជាឆ្នាំ២០១៤បានកើនប្រមាណ១២,៩% (ក្នុងឆ្នាំ២០១៣ទទួលបានជិត៣.១១០លានរៀល) ឆ្នាំ២០១៥បានកើនប្រមាណ១០,៨% ឆ្នាំ២០១៦បានកើនប្រមាណ១៦,៨% និងឆ្នាំ២០១៧បានកើនរហូតដល់១៩,០%នៃថវិកាបណ្តាឆ្នាំមុនៗ។ គិតជារួម

Cambodian Agricultural Research and Development Institute

ក្នុងឆ្នាំ២០១៧នេះ រាជរដ្ឋាភិបាលបានបង្កើនថវិកាឲ្យវិទ្យាស្ថានកាឌី៧៣,៩%ខ្ពស់ជាងឆ្នាំ២០១៣ ដែលក្នុងនោះថវិកាជំពូក៦៤កើនរហូតដល់១៣១,៤% និងថវិកាជំពូក៦៥ កើនបាន៦០,៩%។ ម្យ៉ាងវិញទៀតក្រុមប្រឹក្សាភិបាលក៏បានពិនិត្យនិងអនុម័តលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិការបស់វិទ្យាស្ថានកាឌីឆ្នាំ២០១៦-២០១៨។

ខ.២. ការងារមន្ត្រីរាជការរបស់វិទ្យាស្ថានកាឌី៖ ក្រុមប្រឹក្សាភិបាលបានពិនិត្យនិងផ្តល់ការគាំទ្របេក្ខភាពប្រធានការិយាល័យ០១រូប (ជានារី) និងអនុប្រធាន០៥រូប (នារី០១រូប) តាមការស្នើសុំរបស់វិទ្យាស្ថានកាឌី ហើយបានទទួលលិខិតប្រកាសតែងតាំងពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។

ខ.៣. ការងារលិខិតបទដ្ឋាន៖ ក្រុមប្រឹក្សាភិបាលបានឯកភាពលើ (១)ប្លង់គណនីរបស់វិទ្យាស្ថានកាឌីនិងអនុលោមតាមប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយវិទ្យាស្ថានកាឌីតម្រូវទទួលខុសត្រូវលើការរៀបចំគណនីនិងអនុគណនីលម្អិតនៃប្លង់គណនីនេះ (២)សមាសភាពគណៈកម្មាធិការលទ្ធកម្ម (គល-PC) និងអង្គភាពលទ្ធកម្ម (អល-PU) របស់វិទ្យាស្ថានកាឌី និង (៣)យល់ស្របជាគោលការណ៍ជូនតាមសំណើរបស់វិទ្យាស្ថានកាឌី ដែលសុំដំឡើងថ្នាក់ទៅជាអគ្គនាយកដ្ឋាននិងឯកភាពចំណងជើង "កែសម្រួលដំឡើងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាជាគ្រឹះស្ថានសាធារណៈរដ្ឋបាលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន" ដោយរក្សាឈ្មោះ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ឲ្យនៅដដែល។ សេចក្តីព្រាងនេះ បានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអាណាព្យាបាលបច្ចេកទេស តែមិនទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាណាព្យាបាលហិរញ្ញវត្ថុទេ។ តែទោះជាយ៉ាងណាក្តីកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧ កន្លងមកនេះ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ញើរលិខិតគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីផ្ទាល់តែម្តងដើម្បីសុំដំឡើងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីថ្នាក់នាយកដ្ឋាន ទៅថ្នាក់អគ្គនាយកដ្ឋាន។

កាលពីរសៀលថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ក្រសួងមុខងារសាធារណៈបានបើកកិច្ចប្រជុំមួយទាក់ទងនឹងលិខិតនេះដែលខុទ្ទកាល័យ **សម្តេចតេជោ ហ៊ុន សែន** ផ្ញើរមកឲ្យក្រសួងមុខងារសាធារណៈផ្តល់យោបល់ ដែលក្នុងនោះតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលោក ទី ចាន់ណា ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នាយកវិទ្យាស្ថាននិងសហការី (លោកស្រីនាយិការង សាខន សុផានី លោក សោម ប៊ុណ្ណា លោក ឡោ ប៊ុណ្ណា និងលោក សុក សារ៉ន) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមាន **ឯកឧត្តម អៀង ស៊ីនលី** ជាតំណាង ព្រមទាំងសហការីមួយចំនួន រួមទាំងលោក នួន ជ័យ ផងដែរ។ ជាលទ្ធផល អង្គប្រជុំមិនបានឯកភាពទេដោយសារមានការជំទាស់យ៉ាងខ្លាំងពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ.៤. ការងារដោះស្រាយនិងសម្របសម្រួល៖ ចំពោះការស្នើសុំរបស់ក្រុមហ៊ុន វ៉ានបាវយានអ៊ិនវេសមិនឯ.ក ក្នុងការដូរទីតាំងវិទ្យាស្ថានកាឌី ហើយដែលវិទ្យាស្ថានកាឌីបានបដិសេធនោះ ក្រុមប្រឹក្សាភិបាលគាំទ្រជំហរមិនដោះដូរទីតាំង

Cambodian Agricultural Research and Development Institute

របស់វិទ្យាស្ថានកាឌីជាដាច់ខាត ព្រោះថាការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារពិសោធន៍ផ្ទាល់ មន្ទីរពិសោធន៍និងដំណើរការឧបករណ៍វិភាគ ធនាគារពន្ធុព្រមទាំងដំណាំដាំអភិរក្សនៅលើទីវាលជាដើម មិនមែនងាយស្រួលក្នុងការរើទីតាំងឡើយ ទន្ទឹមនឹងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់វិទ្យាស្ថានកាឌីកំពុងតែត្រូវចំណាយពេលវេលាច្រើនមកធ្វើការស្រាប់ទៅហើយនោះ។ ដូច្នេះបើមានការដូរទីតាំងមែននោះ មន្ត្រីរបស់វិទ្យាស្ថានកាឌីភាគច្រើននឹងចាកចេញ។ ជាពិសេសទៅទៀត ទីតាំងនិងហេដ្ឋារចនាសម្ព័ន្ធរបស់វិទ្យាស្ថានកាឌី ត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មកសម្ពោធដាក់ឲ្យប្រើប្រាស់ចំនួន០២ដង **ហើយសម្តេចតេជោ** ក៏បានប្រកាសថា វិទ្យាស្ថានកាឌីជា **ទារកនិងកូន** របស់សម្តេចផងដែរ។

ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាភិបាលបានពិនិត្យនិងឯកភាពលើសេចក្តីព្រាងរបាយការណ៍ប្រចាំអាណត្តិទី៥និងសម្រេចឲ្យធ្វើការបោះពុម្ព។

ខ.៥. អនុសាសន៍លើការងារ៖ ក្រុមប្រឹក្សាភិបាលបានផ្តល់នូវអនុសាសន៍ល្អៗជាច្រើនដល់វិទ្យាស្ថានកាឌី ជាពិសេសផ្តោតទៅលើ ពង្រឹងការងារស្រាវជ្រាវ ពង្រីកការផ្សព្វផ្សាយបច្ចេកទេស ពិនិត្យលទ្ធភាពជូនក្រុមប្រឹក្សាភិបាលបានចូលរួមសកម្មភាពស្រាវជ្រាវសំខាន់ៗ ជាពិសេសជាមួយកសិករ និងរៀបចំប្រជុំឲ្យបានទៀងទាត់។ ឆ្លើយតបទៅនឹងអនុសាសន៍ទាំងអស់នេះ វិទ្យាស្ថានកាឌីអនុវត្តបានជាសង្ខេបដូចខាងក្រោម៖

**ខ.៥.១. ពង្រឹងការងារស្រាវជ្រាវ៖** ក្នុងរយៈពេល៣ឆ្នាំនេះ វិទ្យាស្ថានកាឌីបានប្រមូលពូជដំណាំថ្មីៗទៀតចំនួន៧ប្រភេទបន្ថែមទៀតដោយមានចំនួនសរុប១.៣៨៩សំណាកមករក្សាទុក បានធ្វើយុវកម្មពូជដំណាំអភិរក្សបានចំនួន៣.០៩២បញ្ជីក/សំណាក បានបញ្ចេញពូជស្រូវចំនួន៥ប្រាំពូជនិងពូជពោតដំណើប១ពូជបន្ថែមទៀត បានរកឃើញវិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចង្រៃនិងជំងឺ ការគ្រប់គ្រងដីនិងទឹក បច្ចេកទេសមុននិងក្រោយពេលប្រមូលផលនិងការប្រើប្រាស់ពូជស្រូវជាដើម ហើយដែលមានលម្អិតនៅក្នុងផ្នែក **ខ**។

**ខ.៥.២. ពង្រីកការងារផ្សព្វផ្សាយបច្ចេកទេស៖** បានបោះពុម្ពរបាយការណ៍សង្ខេបប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំនិងព្រឹត្តិប័ត្រព័ត៌មានកសិករ ហើយបានបោះពុម្ពឡើងវិញនូវសៀវភៅបច្ចេកទេសកសិកម្ម ព្រឹត្តិប័ត្រព័ត៌មានកសិករ និងឯកសារផ្សេងៗបានសរុបចំនួន៩៦.០៩២ច្បាប់ និងបានបែងចែកចំនួនសរុប៩២.៣៨៧ច្បាប់ ស្មើនិង៩៦%។ ក្នុងឆមាសទី២ ឆ្នាំ២០១៧ នេះ បានចងក្រងនិងបោះពុម្ពសៀវភៅ (១)សមិទ្ធផលស្រាវជ្រាវនិងអភិវឌ្ឍន៍រយៈពេល១៨ឆ្នាំ (១៩៩៩-២០១៧) (២)បញ្ជីអភិរក្សពូជស្រូវទី៤ (Rice Germplasm Catalogue IV) និង(៣)បញ្ជីអត្តសញ្ញាណពូជស្រូវនិងពូជដំណាំផ្សេងទៀតដែលបានបញ្ចេញឲ្យប្រើប្រាស់។ បានធ្វើទិវាស្រែបង្ហាញ វាយតម្លៃនិងបណ្តុះបណ្តាលកសិករសរុបចំនួន១៤០លើក ដែលមានកសិករចូលរួមសរុបចំនួន៦.០១២នាក់ ព្រមទាំងបានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន១.៣០៤គ្រួសារ ដោយក្នុងមួយគ្រួសារបានចំនួន៥គីឡូក្រាម មានសរុបចំនួន៦.៥២០គក្រ ហើយដែលកសិករទាំងនោះផលិតជាគ្រាប់ពូជបានប្រមាណ១៨៣តោន (គិតមកត្រឹមដំណាច់ឆ្នាំ២០១៦) ទុកសម្រាប់ប្រើប្រាស់ក្នុងឆ្នាំបន្ទាប់។ ទន្ទឹមនឹងនេះ បានចែកគ្រាប់ពូជគ្រឹះនៃពូជស្រូវស្មាច់០២ ដែលទើបបញ្ចេញជូនកសិករសហគមន៍កសិកម្មស្រូវស្មាច់កំពង់រោទិ៍ចំនួនប្រមាណ២០០គក្រ សម្រាប់ដាំដុះក្នុងឆ្នាំ២០១៧

Cambodian Agricultural Research and Development Institute

និងបានចែកគ្រាប់ពូជស្រូវដំណើបស្បែមង្គលជូនសហគមន៍ក្រឡានថ្មគ្រែខេត្តក្រចេះដាំដុះ សម្រាប់ដុតក្រឡានផងដែរ។ ថ្នាក់ដឹកនាំបានចូលរួមជាវាគ្មិនក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុបានចំនួន០៧លើកនិងបានទទួលជួបភ្ញៀវជាតិនិងអន្តរជាតិចំនួន១៧៩លើកដែលមានភ្ញៀវសរុប៦៦៦នាក់។

**ខ.៥.៣. ការចូលរួមក្នុងសកម្មភាពផ្សេងៗ៖** ក្រុមប្រឹក្សាភិបាលចូលរួមក្នុងពិធីសូត្រមន្តចូលឆ្នាំថ្មីរបស់វិទ្យាស្ថានកាឌីដែលប្រព្រឹត្តទៅនាថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧។

## គ. ផ្នែកព្រឹត្តការណ៍សំខាន់ៗនិងការងារគ្រប់គ្រងរបស់វិទ្យាស្ថានកាឌី

ក្រុមប្រឹក្សាភិបាលបានពិនិត្យនិងទទួលស្គាល់ថា ក្នុងរយៈពេល០៤ឆ្នាំនេះ វិទ្យាស្ថានកាឌីបានចូលរួមក្នុងព្រឹត្តការណ៍សំខាន់ៗជាច្រើន ហើយបានបន្តការគ្រប់គ្រងបុគ្គលិកនិងថវិកាបានល្អគួរជាទីមោទនភាពដូចខាងក្រោម៖

គ.១. ព្រឹត្តការណ៍សំខាន់ៗ និងការចូលរួមរបស់ថ្នាក់ដឹកនាំវិទ្យាស្ថានកាឌី៖

នាពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងរយៈពេល៣ឆ្នាំ (២០១៥ ២០១៦ និង២០១៧) កន្លងមកនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានវាយតម្លៃខ្ពស់ដល់វិទ្យាស្ថានកាឌី ដែលបានបញ្ចេញពូជស្រូវថ្មីធន់នឹងការប្រែប្រួលអាកាសធាតុចំនួន៥ពូជ និងពូជពោតដំណើប១ពូជ និងជាពិសេស នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ **សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ថា វិទ្យាស្ថានកាឌី នឹងត្រូវដើរតួកាន់តែសកម្មនៅក្នុងបរិការដែលពិភពលោកស្ថិតក្នុងពេលវេលាដ៏លំបាក ទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងបានលើកទឹកចិត្តឲ្យមន្ត្រីរាជការនិងអ្នកបច្ចេកទេសនៅវិទ្យាស្ថានកាឌី បន្តស្វែងរកពូជស្រូវថ្មីៗ និងពូជដំណាំផ្សេងទៀត រួមទាំងផ្កាផងដែរ។

បានចូលរួមជាវាគ្មិនក្នុងពិធីបុណ្យអង្គរកម្ពុជាលើកទី២ ឆ្នាំ២០១៤ នៅខេត្តសៀមរាប និងចូលរួមជាវាគ្មិន និងតាំងពិព័រណ៍ស្រូវ-អង្ករក្នុងវេទិកាស្រូវអង្ករឆ្នាំ២០១៤ នៅសណ្ឋាគារសូហ្វីតែលភូគីត្រា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលពិព័រណ៍និងសន្និបាតកោះពេជ្រ និង២០១៦ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ ដែលក្នុងនោះអង្ករផ្ការំដួលនៃពូជស្រូវផ្ការំដួល ដែលបញ្ចេញដោយវិទ្យាស្ថាន ទទួលបានជ័យលាភីលេខ១ លើពិភពលោកប្រចាំឆ្នាំ២០១៤ ដែលជាជ័យលាភី៣ឆ្នាំ បន្តបន្ទាប់គ្នាចាប់តាំងពីឆ្នាំ២០១២-២០១៤។ ក្នុងវេទិកាស្រូវ-អង្ករលើកទី៥ (ឆ្នាំ២០១៦) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន** ដែលប្រារព្ធនៅសណ្ឋាគារសុខា រាជធានីភ្នំពេញ **សម្តេចតេជោ** បានបញ្ជាឲ្យវិទ្យាស្ថានកាឌី បន្តផលិតគ្រាប់ពូជគ្រឹះរបស់ពូជស្រូវដែលបានបញ្ចេញជូនកសិករប្រើប្រាស់ជាបន្តទៀត ដើម្បីធានានូវភាពសុទ្ធរបស់គ្រាប់ពូជ ផ្គត់ផ្គង់ដល់អ្នកផលិតចំណាត់បន្តបន្ទាប់ទៀត។

វិទ្យាស្ថានកាឌីបានចូលរួមតាំងពិព័រណ៍ស្រូវ-អង្ករក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ទិវាប្រយុទ្ធប្រឆាំងនឹងឱនភាពដីទិវាស្បៀងអាហារពិភពលោក និងបានចូលរួមរៀបចំពិធីបុណ្យរំឭកខួបទី៣០ នៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជានិងវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងឱកាសនោះ ថ្នាក់ដឹកនាំនិងមន្ត្រីក្រោមឱវាទវិទ្យាស្ថានកាឌីចំនួន៤រូបបានទទួលស្លាកកោតសរសើរការងារពី IRRI។

Cambodian Agricultural Research and Development Institute

លោកបណ្ឌិត អ៊ុក ម៉ាការា នាយកវិទ្យាស្ថានកាឌី បានត្រូវក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើសជា អ្នកវិទ្យាសាស្ត្រឆ្នើម ប្រចាំឆ្នាំសិក្សា២០១៦–២០១៧ និងត្រូវបាន ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បំពាក់គ្រឿងឥស្សរិយយសមុនីសារភ័ណ្ឌ ថ្នាក់មហាសិរីវឌ្ឍន៍ ជូននាឱកាសពិធីបិទសន្និបាតបូកសរុបប្រចាំ ឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិបច្ចេកវិទ្យា។

បានទទួលគណៈប្រតិភូមកពីប្រទេសបង់ក្លាដេសចំនួន៦រូប ដែលដឹកនាំដោយ Mr. Md. Hemayet Uddin, Deputy Secretary នៃក្រសួងកសិកម្មប្រទេសបង់ក្លាដេស។

ថ្នាក់ដឹកនាំវិទ្យាស្ថានកាឌីបានចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗនៅក្នុងក្រសួង និងស្ថាប័ននានាក្នុងប្រទេសចំនួន ៣៣៤លើក និងក្រៅប្រទេសចំនួន៤៤លើក ហើយបានទទួលជួបភ្ញៀវជាតិនិងអន្តរជាតិនៅវិទ្យាស្ថានកាឌីចំនួន ១៧៩លើក ដែលមានភ្ញៀវសរុប៦៦៦នាក់។

គ.២. ស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិក៖

តារាង១. ស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកក្រោមឱវាទវិទ្យាស្ថានកាឌីឆ្នាំ២០១៤-២០១៧

| ល.រ | បរិយាយ | ប្រចាំឆ្នាំ (នាក់) | | | |
|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
| ក. មន្ត្រីរាជការស៊ីវិល | | | | | |
| ១ | ថ្នាក់បណ្ឌិត | ៥ | ៥ | ៦ | ៨ |
| ២ | និស្សិតថ្នាក់បណ្ឌិត | | | | ២ |
| ៣ | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១៦ | ១៦ | ១៧ | ១៣ |
| ៤ | និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | | | | ៤ |
| ៥ | ថ្នាក់បរិញ្ញាបត្រ | ២៣ | ២១ | ២៧ | ៣០ |
| ៦ | កម្រិតវប្បធម៌ទូទៅ | ៨ | ៨ | ៧ | ៦ |
| សរុប ក | | ៥២ | ៥១ | ៥៧ | ៦៣ |
| ខ. មន្ត្រីជាប់កិច្ចសន្យា | | | | | |
| ១ | ថ្នាក់បណ្ឌិត | - | - | ១ | ១ |
| ២ | ថ្នាក់បរិញ្ញាបត្រ | ៨ | ៨ | ២៩ | ២៧ |
| ៣ | កម្រិតវប្បធម៌ទូទៅ | - | - | ៥៥ | ៥៥ |
| សរុប ខ | | ៨ | ៨ | ៨៥ | ៨៣ |
| គ. ពលករអណ្តែត | | | | | |
| ១ | កម្រិតវប្បធម៌ទូទៅ | ១០០ | ១០០ | - | - |
| សរុប គ | | ១០០ | ១០០ | - | - |
| សរុបរួម | | ១៦០ | ១៥៩ | ១៤២ | ១៤៦ |

Cambodian Agricultural Research and Development Institute

ស្ថានភាពបុគ្គលិករបស់វិទ្យាស្ថានកាឌីមានការថយចុះពី១៦០នាក់ក្នុងឆ្នាំ២០១៤ មក១៤៦នាក់ក្នុងឆ្នាំ២០១៧ ដូចមានបង្ហាញក្នុងតារាង១។ មន្ត្រីរាជការបានកើនឡើងចំនួន១២នាក់ក្នុងឆ្នាំ២០១៧ ធៀបជាមួយនឹងឆ្នាំ២០១៣ កន្លងមក។ មន្ត្រីរាជការថ្នាក់បណ្ឌិតបានកើនពី៥នាក់ក្នុងឆ្នាំ២០១៤ មក៨នាក់ក្នុងឆ្នាំ២០១៧ ហើយផ្ទុយមកវិញ ចំនួនមន្ត្រីរាជការថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់បានថយពី១៦នាក់ មក១៣នាក់។ ទន្ទឹមនឹងនោះ មានមន្ត្រីរាជការចំនួន ០២នាក់កំពុងសិក្សាថ្នាក់បណ្ឌិត និង០៤នាក់កំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់។ ក្នុងឆ្នាំ២០១៦និង២០១៧ រាជរដ្ឋាភិបាលបានសម្រេចឲ្យវិទ្យាស្ថាននូវមន្ត្រីជាប់កិច្ចសន្យាចំនួន៨៥នាក់ក្នុងឆ្នាំ២០១៦ និង៨៣នាក់ក្នុងឆ្នាំ ២០១៧ ជំនួសឲ្យពលករអណ្តែត។

គ.៣. ស្ថានភាពហិរញ្ញវត្ថុ៖ ថវិការាជរដ្ឋាភិបាលបានអនុម័តប្រគល់ឲ្យវិទ្យាស្ថានមានការកើនឡើងជារៀងរាល់ឆ្នាំធៀបនឹងឆ្នាំ២០១៣ដែលមានប្រមាណជិត៣.១១០លានរៀល។ ថវិកាឆ្នាំ២០១៤បានកើនប្រមាណ១២,៩% ឆ្នាំ២០១៥ បានកើនប្រមាណ១០,៨% ឆ្នាំ២០១៦បានកើនប្រមាណ១៦,៨% និងឆ្នាំ២០១៧បានកើនរហូតដល់១៩,០%នៃថវិកាបណ្តាឆ្នាំមុនៗ។ សម្រាប់ឆ្នាំ២០១៧នេះ រាជរដ្ឋាភិបាលបានបង្កើនថវិកាឲ្យវិទ្យាស្ថានកាឌី៧៣,៩%ខ្ពស់ជាងឆ្នាំ២០១៣ ដែលក្នុងនោះ ថវិកាជំពូក៦៤កើនរហូតដល់១៣១,៤% និងថវិកាជំពូក៦៥ កើនបាន៦០,៩%។

តារាង២. ស្ថានភាពហិរញ្ញវត្ថុរបស់វិទ្យាស្ថានកាឌីពីឆ្នាំ២០១៣-២០១៧

| ល.រ | បរិយាយ | ប្រចាំឆ្នាំ (គិតជាប្រាក់រៀល) | | | | |
|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) |
| I. **លទ្ធផលហិរញ្ញវត្ថុ** | | | | | | |
| ១ | **ស្ថានភាពចំណូលដុល** | **3,336,612,540** | **3,641,525,910** | **3,975,185,962** | **4,618,317,493** | **5,625,854,784** |
| ក | ចំណូលពីថវិការដ្ឋឧបត្ថម្ភ | 3,073,865,630 | 3,455,089,659 | 3,872,852,203 | 4,543,059,505 | 5,338,000,000 |
| ខ | ចំណូលពីសកម្មភាពអាជីវកម្ម | 226,746,910 | 131,661,631 | 86,004,687 | 74,322,849 | 217,000,000 |
| គ | សមតុល្យបូកយោង | 36,000,000 | 54,774,620 | 577,051 | 935,139 | 70,854,784 |
| ឃ | សមតុល្យបង្កកដែលបានកែតម្រូវ (ពុំបានកត់ត្រា) លើសំណែសចំណាយបៀវត្ស | | | 15,752,020 | | |
| ២ | **ស្ថានភាពចំណាយ** | **3,281,837,920** | **3,640,948,859** | **3,958,498,803** | **4,622,583,705** | **5,645,000,000** |
| ក | បៀវត្ស លាភការ ប្រាក់ពលករអណ្តែត និងបុគ្គលិកជាប់កិច្ចសន្យា | 573,865,630 | 619,699,600 | 699,027,500 | 1,039,119,300 | 1,238,000,000 |
| ខ | ចំណាយដំណើរការរដ្ឋបាលទូទៅ | 1,257,665,950 | 1,141,249,259 | 863,159,237 | 888,012,405 | 1,046,000,000 |
| គ | ចំណាយប្រតិបត្តិការលើសកម្មភាពពិសោធន៍ស្រាវជ្រាវ និងអភិវឌ្ឍន៍ | 1,450,306,340 | 1,880,000,000 | 2,396,312,066 | 2,695,452,000 | 3,271,000,000 |
| ៣ | **លទ្ធផលហិរញ្ញវត្ថុ** | **54,774,620** | **577,051** | **935,139** | **70,854,784** | |
| ក | សំណែសចំណាយថវិការដ្ឋចុងឆ្នាំដែលត្រូវបង្វែរចូលថវិកាជាតិវិញ | | | 15,752,020* | (12,000,000 )** | |
| ខ | សមតុល្យបង្គរថវិកាចំណូលពីអាជីវកម្ម | 18,774,620 | 577,051 | 358,087 | 87,120,996 | 23,564,051 |
| II **ឥណទេយ្យ និងបំណុលតតិយជន** | | | | | | |
| ៤ | **បំណុលតតិយជន** | - | - | - | | |
| ក | បំណុលត្រូវទារ | 11,938,020.00 | 3,814,000.00 | - | 23,564,051.36 | |
| ខ | បំណុលត្រូវសង/ចំណាយពុំទាន់បានទូទាត់ | - | - | - | 4,262,500.00 | |

__បញ្ជាក់:__ * សំណែសចំណាយប្រាក់បៀវត្សមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៣-២០១៤ = ១៥.៧៥២.០២០រៀល

** សំណែសចំណាយប្រាក់បុគ្គលិកជាប់កិច្ចសន្យាសម្រាប់ឆ្នាំ២០១៦ = ១២.០០០.០០០រៀល

Cambodian Agricultural Research and Development Institute

ក្នុងជំពូក៦៥ ក្រុមប្រឹក្សាភិបាលបានសម្រេចបង្កើនថវិកាភាគច្រើនទៅលើសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា គឺពីប្រមាណ១,៥០០លានរៀលក្នុងឆ្នាំ២០១៣ ដល់៣,២៧១លានរៀល (ប៉ាន់ស្មាន) សម្រាប់ឆ្នាំ២០១៧ ចំណែក ថវិកាដំណើរការរដ្ឋបាលទូទៅ គឺមានការថយចុះពីជិត១,២៥៨លានរៀលក្នុងឆ្នាំ២០១៣ មក១,០៤៦លានរៀល (ប៉ាន់ស្មាន) សម្រាប់ឆ្នាំ២០១៧។

## ឃ. សមិទ្ធផលរួមឆ្លើយតបទៅនឹងសូចនាករក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨

តារាង៣. លទ្ធផលឆ្លើយតបទៅនឹងសូចនាករដែលបានព្យាករណ៍ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨

| សូចនាករលទ្ធផល | ឯកតា | ឆ្នាំ២០១៤ | | ឆ្នាំ២០១៥ | | ឆ្នាំ២០១៦ | | ឆ្នាំ២០១៧ | |
|---|---|---|---|---|---|---|---|---|---|
| | | ព្យាករណ៍ | អនុវត្តបាន | ព្យាករណ៍ | អនុវត្តបាន | ព្យាករណ៍ | អនុវត្តបាន | ព្យាករណ៍ | អនុវត្តបាន |
| អនុកម្មវិធីទី១.១៨. ស្រាវជ្រាវដើម្បីលើកកម្ពស់ផលិតភាពដំណាំកសិកម្ម | | | | | | | | | |
| ១. ចំនួនពូជដំណាំដែលត្រូវបានប្រមូលបន្ថែម | សំណាក | ១០០ | ៣៩១ | ១០០ | ៣២៤ | ១០០ | ៤០៤ | ១០០ | |
| ២. ប្រភេទពូជដំណាំថ្មីៗដែលត្រូវបានបញ្ចេញ | ពូជ | ២ | ០ | ១ | ៤ | ២ | ២ | ២ | |
| ៣. បច្ចេកទេសថ្មីៗដែលត្រូវបានបង្កើត | ចំនួន | ៧ | ៨ | ៦ | ៦ | ៧ | ១៣ | ៧ | |
| អនុកម្មវិធីទី១.១៩.ស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្ម និងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម | | | | | | | | | |
| ១. បង្គុំបច្ចេកវិទ្យាពិពិធកម្មដំណាំស្រូវជាមូលដ្ឋានត្រូវបានបញ្ចេញ | ចំនួន | ២ | ១ | ១ | ១ | ១ | ០ | ១ | |
| ២. កំណើនផ្ទៃដីដាំដុះដោយពូជស្រូវនិងបច្ចេកទេសថ្មីៗដែលបញ្ចេញដោយកាឌី | % | ២ | ២ | ២ | ២ | ២ | ២ | ២ | |
| ៣. បរិមាណគ្រាប់ពូជដំណាំដែលមានភាពសុទ្ធខ្ពស់និងគុណភាពល្អ | តោន | ៥០ | ១០២ | ៥៥ | ៧៨ | ៥៥ | ១១៧ | ៥៥ | |
| អនុកម្មវិធីទី១.២០.បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្សផ្នែកពិសោធន៍ស្រាវជ្រាវ | | | | | | | | | |
| ១. មន្ត្រីបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តមនិងឱកាសសិក្ខាកាមទទួលបានការបណ្តុះបណ្តាល | ឱកាស | ១០៥ | ៧៨១ | ១០៥ | ៦៨៦ | ១០៥ | ១៩៦ | ១០៥ | |
| ២. ឯកសារវិទ្យាសាស្ត្របោះពុម្ពផ្សាយ | ប្រភេទ | ២ | ១៤ | ៣ | ៩ | ៥ | ៨ | ៦ | |
| ៣. កំណើនប្រសិទ្ធភាពនៃប្រព័ន្ធទ្រទ្រង់ក្នុងការផ្តល់សេវាស្រាវជ្រាវដល់សេដ្ឋកិច្ច | % | ២ | ២ | ២ | ២ | ២ | ១៤ | ២ | |

Cambodian Agricultural Research and Development Institute

ក្រុមប្រឹក្សាភិបាលអាណត្តិទី៥បានទទួលស្គាល់ថា ការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអាណាព្យាបាលផ្នែកបច្ចេកទេស និងមានការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ចជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ រួមទាំងកិច្ចសហការពីអង្គភាពជំនាញនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពស្រាវជ្រាវអន្តរជាតិនានា និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសប្រជាកសិករកម្ពុជា វិទ្យាស្ថានកាឌីសម្រេចបាននូវលទ្ធផលគួរជាទីមោទនស្របទៅតាមសូចនាករ ដែលបានព្យាករណ៍ទុកដូចមានបង្ហាញក្នុងតារាង៣។

## ខ. សមិទ្ធផលនៃការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងផ្ទេរបច្ចេកវិទ្យាក្នុងឆ្នាំ២០១៤–២០១៧

អនុវត្តតាមតួនាទីនិងភារកិច្ចរបស់ខ្លួន ជាពិសេសដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤–២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការសម្រេចឲ្យបាននូវគោលនយោបាយចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៣ឆ្នាំនេះ ក្រុមប្រឹក្សាភិបាលបានចូលរួមដោះស្រាយនិងលើកទឹកចិត្តដល់វិទ្យាស្ថានកាឌី ឲ្យបន្តការខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំនូវការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាលើ (១)ការអភិវឌ្ឍពូជដំណាំផ្សេងៗ រួមមានស្រូវ ពោត សណ្តែក ដំឡូងមី បន្លែ ឈើហូបផ្លែ ដំណាំលម្អ (២)ការគ្រប់គ្រងដីជាតិដីនិងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍបច្ចេកទេសដាំដុះនិងប្រព័ន្ធកសិកម្ម (៤)កិច្ចការពារដំណាំពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗ (៥)ការអភិវឌ្ឍបច្ចេកទេសមុននិងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្ម និង(៧)ការបណ្តុះបណ្តាល ការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសនិងព័ត៌មានកសិកម្ម។ ជារួម បានធ្វើពិសោធន៍ជាមធ្យមចំនួន១០០ប្រភេទក្នុងមួយឆ្នាំ ហើយដែលមានចំនួនសរុប២.៤២៨កន្លែង រួមទាំងការអង្កេត ទិវាស្រែបង្ហាញ និងបណ្តុះបណ្តាលជាច្រើន ដោយទទួលបានលទ្ធផលទៅតាមគោលបំណងនិងសូចនាករក្នុងអនុកម្មវិធីទាំង៣ តាមលំដាប់លំដោយដូចខាងក្រោម។

### ង.១. ការងារអភិរក្សពូជដំណាំ

ការអភិរក្សពូជដំណាំ: បានប្រមូលពូជដំណាំថ្មីៗទៀតចំនួន៧ប្រភេទបន្ថែមទៀត មានចំនួនសរុប១.៣៨៩សំណាកមករក្សាទុក និងបានធ្វើយុវកម្មពូជដំណាំអភិរក្សបានចំនួន៣.០៩២បញ្ចឹក/សំណាក ដោយក្នុងនោះមានពូជដំណាំចំនួន៨៦ខូចទាំងស្រុង។ គិតជារួមត្រឹមខែតុលា ឆ្នាំ២០១៧នេះ ពូជដំណាំសរុបចំនួន៣៨ប្រភេទដែលរួមមានស្រូវចំនួន៦.៦៩២បញ្ចឹក/សំណាក និងដំណាំផ្សេងៗចំនួន៣៧ប្រភេទរួមមាន១.៥៦៩បញ្ចឹក/សំណាក ដែលសរុបទាំងអស់មានចំនួន៨.២៦១បញ្ចឹក/សំណាកបានអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថានកាឌី សម្រាប់ប្រើប្រាស់ក្នុងកិច្ចអភិវឌ្ឍន៍ពូជដំណាំក្នុងរយៈពេលយូរអង្វែង។ ទន្ទឹមនឹងនេះ បានចុះកិច្ចព្រមព្រៀងអភិរក្សពូជដំណាំរយៈពេលយូរនៅរដ្ឋបាលអភិវឌ្ឍន៍ជនបទកូរ៉េនិងបានយកពូជស្រូវចំនួន២១៤បញ្ចឹកទៅរក្សាទុករយៈពេលយូរនៅធនាគាពន្ធុប្រទេសកូរ៉េ។

### ង.២. ការបញ្ចេញពូជដំណាំថ្មីៗ

វិទ្យាស្ថានកាឌីបានបញ្ចេញពូជស្រូវថ្មីចំនួន០៥និងពូជពោតចំនួន០១បន្ថែមទៀត ដែលមានឈ្មោះនិងលក្ខណៈពិសេសៗដូចខាងក្រោម៖

ង.២.១. ពូជស្រូវ ខា១៤ (CAR14)៖ បានបញ្ចេញនាដើមឆ្នាំ២០១៥ ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវ ធន់ទ្រាំទៅនឹងជំងឺប្លាស់ មានប្រភពដើមពីអ៊ីរី (IR06L164) ។ ពូជនេះជាមធ្យម មានអាយុកាល៩៥ថ្ងៃ (ព្រោះ) កម្ពស់០,៩ម



Cambodian Agricultural Research and Development Institute

ប្រវែងគ្រាប់អង្ករ៦,៨មម បន្ទារកម្រាស់១,៨មម មានកម្រិតអាមីឡូស១៨,៦% និងទិន្នផល៤,២ត/ហត។ ពូជស្រូវខា១៤ (CAR14, CAR= Cambodian Rice) អាចផ្តល់ផលរហូតដល់៧,៥ត/ហត។

ង.២.២. ពូជស្រូវ ខា១៥ (CAR15)៖ ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវ មានប្រភពដើមពីអុីរី (IR04N155) បញ្ចេញក្នុងឆ្នាំ២០១៦។ ពូជនេះជាមធ្យមមានអាយុកាល១០០ថ្ងៃ កម្ពស់១,០ម ប្រវែងគ្រាប់អង្ករ៧,០មម បន្ទារគ្រាប់២,១មម មានកម្រិតអាមីឡូស២១,៦% និងទិន្នផលមធ្យមទាំងរដូវប្រាំងនិងវស្សា៤,០ត/ហត ព្រមទាំងធន់ទ្រាំមធ្យមទៅនឹងមមាចត្នោត។ ពូជស្រូវខា១៥ អាចផ្តល់ផលរហូតដល់៧,៤ត/ហត។

ង.២.៣. ពូជស្រូវ ខា១៦ (CAR16)៖ ជាពូជស្រូវស្រាលមិនប្រកាន់រដូវធន់នឹងកម្តៅខ្ពស់ និងមានប្រភពដើមពីអុីរី (IR10L149)។ ពូជនេះជាមធ្យមមានអាយុកាល៩៨ថ្ងៃ កម្ពស់១,០ម ប្រវែងគ្រាប់អង្ករ៧,២មម បន្ទារគ្រាប់១,៨មម មានកម្រិតអាមីឡូស២៥,១% និងទិន្នផលមធ្យមទាំងរដូវប្រាំងនិងវស្សា៤,១ត/ហត។ ពូជស្រូវខា១៦ អាចផ្តល់ផល រហូតដល់៦,៨ត/ហត ហើយដែលជាពូជស្រូវដែលបានធ្វើការពិសោធន៍ វាយតម្លៃ និងជ្រើសរើសតាំងពីឆ្នាំ២០១១ ដោយផ្តោតទៅលើភាពធន់ទ្រាំទៅនឹងការកើនឡើងកម្តៅបរិយាកាស។ ក្នុងលក្ខខណ្ឌផ្ទះកញ្ចក់មានសីតុណ្ហភាពមធ្យមអតិបរមា៤៥°c នៃរយៈពេល១៤ថ្ងៃមុននិងក្រោយថ្ងៃចេញផ្កា៥០% (រូបភាព១) ពូជស្រូវខា១៦ ដាក់គ្រាប់បានរហូតដល់៧១% ច្រើនជាងពូជស្រូវដទៃទៀតដែលមានយ៉ាងច្រើនត្រឹម៦២% (ពូជជលសារ) ទន្ទឹមនឹងក្នុងផ្ទះសំណាញ់ដែលមានសីតុណ្ហភាពមធ្យមអតិបរមា៤០°c ពូជស្រូវខា១៦ ដាក់គ្រាប់បានប្រហាក់ប្រហែលពូជដទៃទៀត (រូបភាព១, ២ និងក្រាហ្វិក១)។


រូបភាព១.លក្ខខណ្ឌផ្ទះកញ្ចក់


រូបភាព២.លក្ខខណ្ឌផ្ទះសំណាញ់



ក្រាហ្វិក១. ភាគរយគ្រាប់ដាក់ក្នុងមួយកួរ (y)

ង.២.៤. ពូជស្រូវ ផ្ការំដួលប្រាំង (Phka Rumduol Prang)៖ បានបញ្ចេញក្នុងឆ្នាំ២០១៥ ដែលជាពូជស្រូវក្រអូបប្រណីតដូចពូជស្រូវផ្ការំដួលវស្សាដែរ សមស្របដាំដុះនារដូវទឹកសម្រកចាប់ពាក់កណ្តាលខែតុលានិងក្នុងខែវិច្ឆិកា ដោយប្រមូលផលនាខែកុម្ភៈនិងដើមខែមីនា ដោយសារពូជស្រូវនេះនៅប្រកាន់រដូវខ្សោយនៅឡើយ។ ទិន្នផលអាចដល់៤,៥ត/ហត ជាមធ្យមមានកម្ពស់១,១ម ប្រវែងកួរ២២សម និងទម្ងន់ស្រូវ១០០គ្រាប់២,៩ក្រ។ អង្ករលូនវែងមានប្រវែងគ្រាប់៧,២មម បន្ទារកម្រាស់២,១មម និងមានកម្រិតអាមីឡូស១៤,៨%។

ង.២.៥. ពូជស្រូវ ស្ពាច់០២ (Smach02)៖ ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ចេញផ្កានាចុងខែវិច្ឆិកានិងដើមខែធ្នូ សមស្របសម្រាប់ដីជម្រៅខ្លាំងនៃស្រែទំនាបរំពឹងទឹកភ្លៀង។ ពូជស្រូវស្ពាច់០២នេះ វិទ្យាស្ថានកាឌីបានធ្វើជម្រើសឯកត្តៈពីពូជស្រូវស្ពាច់ប្រពៃណីរបស់កសិករនៅសហគមន៍កសិកម្មស្រូវស្ពាច់កំពង់រោទិ៍ចាប់ពីឆ្នាំ២០១២ តាមរយៈការស្នើសុំពីសហគមន៍និងលោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ហើយបានបញ្ចេញក្នុងឆ្នាំ២០១៦។ ពូជស្រូវនេះជាមធ្យម មានកម្ពស់១,៥ម ប្រវែងគ្រាប់អង្ករ៦,៥មម បន្ទារគ្រាប់១,៨មម មានកម្រិតអាមីឡូស១៨,៤% និងទិន្នផលមធ្យម៣,២ត/ហត ព្រមទាំងអាចផ្តល់ផលរហូតដល់៤,២ត/ហត។

Cambodian Agricultural Research and Development Institute



រូបភាព៣. ទិវាបញ្ចេញនិងចែកគ្រាប់ពូជស្រូវ ស្នាច់០២ ជូនកសិករសហគមន៍កសិកម្មស្រូវស្នាច់កំពង់រោទិ៍

ង.២.៦. ពូជពោតដំណើប ស៊ីអឹម១ (CM1)៖ បានបញ្ចេញក្នុងឆ្នាំ២០១៥ ជាពោតដំណើបដែលកសិករអាចទុកពូជដាំបន្តទៀតបាន។ ពូជស៊ីអឹម១ (CM1, CM=Cambodian maize) ជាមធ្យមផ្កាឈ្មោលចេញក្នុងរយៈពេល៣៧ថ្ងៃ និងផ្កាញីក្នុងរយៈពេល៤០ថ្ងៃបន្ទាប់ពីដាំ ដើមមានកម្ពស់១,៧ម ផ្លែមានប្រវែង១៧សម ចំនួនផ្លែក្នុង១ដើមមានចំនួន១ និងទិន្នផលគ្រាប់ទុំ៦ត/ហត។ ពូជនេះ អាចដាំដុះបាននៅតំបន់ចម្ការនិងស្រែទំនាបរំពឹងទឹកភ្លៀងបន្ទាប់ពីប្រមូលផលស្រូវវស្សារួចភ្លាម។

## ង.៣. ការងារស្រាវជ្រាវនិងអង្កេតលើដំណាំស្រូវ

ង.៣.១. ប្រសិទ្ធភាពនៃរបបទឹកនិងកម្រិតជីអាសូតទៅលើទិន្នផលស្រូវដាំដុះលើក្រុមដីប្រទះឡាង៖ លទ្ធផលនៃការសិក្សានៅក្នុងលក្ខខណ្ឌផ្ទះកញ្ចក់និងវាលស្រែក្នុងវិទ្យាស្ថានបានបង្ហាញថា (១)នៅក្នុងលក្ខខណ្ឌផ្ទះកញ្ចក់ ការស្រោចស្រពតាមវិធីសាស្ត្រសមត្ថភាពចាប់យកទឹករបស់ដីស្រែ (Field capacity) ពុំបានបង្កើនប្រសិទ្ធភាពការប្រើប្រាស់ប្រាស់ជីឡើយ ទោះបីកម្រិតជីអាសូតត្រូវបានបង្កើនរហូតដល់បរិមាណ១៥០គក្រ/ហតក៏ដោយ (ក្រាហ្វិក២)។




ក្រាហ្វិក២. កម្រិតជីអាសូត (x, N rate) និងទម្ងន់គ្រាប់ស្ងួតជាមធ្យម (y, Grain weight) ក្នុងរបបទឹកលិចជាប្រចាំ (Flooded) ឆ្អែតទឹក (Saturated) និងសមត្ថភាពចាប់យកទឹករបស់ដីស្រែ (Field capacity) ក្រុមដីប្រទះឡាង

ចំពោះការស្រោចស្រពក្នុងកម្រិតដីឆ្អែតទឹក (Saturated) បានបង្កើនប្រសិទ្ធភាពការប្រើប្រាស់ជីគួរឲ្យកត់សម្គាល់ បើកម្រិតអាសូតត្រូវបានបង្កើនរហូតដល់១០០គក្រ/ហត ដោយទិន្នផលទទួលបានប្រមាណ១៤,៨ក្រ/គុម្ព។ ប៉ុន្តែការបង្កើនកម្រិតអាសូតរហូតដល់១៥០គក្រ/ហត មិនបានបង្កើននូវប្រសិទ្ធភាពនៃការប្រើប្រាស់ជីឡើយ ដោយទិន្នផលទទួលបានប្រមាណ១៤,១ក្រ/គុម្ព។ ដោយឡែកការស្រោចស្រពតាមលក្ខខណ្ឌដីដាក់ទឹក៥សម ជាប់ជាប្រចាំ (Flooded) បានជួយជំរុញឲ្យការប្រើប្រាស់ជីអាសូតប្រកបដោយប្រសិទ្ធភាព ហើយទិន្នផលមានការកើនឡើងចន្លោះពី១២,៥ក្រ/គុម្ព (មិនដាក់ជី) រហូតដល់២៣,១ក្រ/គុម្ព បើជីអាសូតត្រូវបានបង្កើនរហូតដល់១៥០គក្រ/

Cambodian Agricultural Research and Development Institute

ហត និង (២)នៅក្នុងវាលស្រែ ការបង្កើនកម្រិតអាសូតមួយកម្រិតកន្លះណែនាំសម្រាប់ក្រុមដីប្រទះឡាងមិនបានជួយដល់ការលូតលាស់និងទិន្នផលស្រូវស្រាលនោះទេ។ ដោយឡែកកត្តានៃរបបទឹកបានកំណត់ឥទ្ធិពលទៅលើការដុះលូតលាស់និងទិន្នផលស្រូវ ហើយការពន្លិចទឹកជាប់ទទួលបានទិន្នផលខ្ពស់ជាងគេគឺជាមធ្យម៣,៦ត/ហត ដោយបានប្រើប្រាស់ទឹកក្នុងបរិមាណ៦.៧៦០ម³/ហតឬ៦៧៦មម បន្ទាប់មកគឺការកំណត់ពេលវេលាក្នុងការស្រោចស្រព (ដក់ទឹក១៥ថ្ងៃនិងមិនដក់ទឹក១៥ថ្ងៃ) ទទួលបានទិន្នផលជាមធ្យម២,៩ត/ហត ដោយបានប្រើប្រាស់ទឹកអស់បរិមាណ៣.៩៧០ម³/ហត។ ចំណែកឯការស្រោចស្រពត្រឹមកម្រិតឲ្យដីសើមដោយបានប្រើប្រាស់ទឹកអស់បរិមាណ២.៧៤០ម³/ហត គឺទទួលបានទិន្នផលទាបជាងគេ ដែលជាមធ្យម២,០ត/ហត។

ង.៣.២. តុល្យតាពទឹកនៃដំណាំស្រូវ៖ លទ្ធផលនៃការតាមដាននិងពិសោធន៍រយៈពេល៥ឆ្នាំកន្លងមកបានបង្ហាញថា (១)រំហួតបរិយាកាស (Pan evaporation) មានជាមធ្យម៥មម/ថ្ងៃ ក្នុងនោះទាបបំផុតក្នុងខែធ្នូមាន៤មម/ថ្ងៃ និងខ្ពស់បំផុតក្នុងខែមីនាមាន៦មម/ថ្ងៃ ហើយមធ្យមរដូវប្រាំងមាន៥,១មម/ថ្ងៃ និងរដូវវស្សាមាន៤,៩មម/ថ្ងៃ (២) ក្នុងដំណាំស្រូវរដូវប្រាំង មានរំហួតពីផ្ទៃទឹក (Evaporation) ជាមធ្យម៤,១មម/ថ្ងៃ និងដោយដំណកដង្ហើម (Transpiration) ១,៦មម/ថ្ងៃ និង(៣) ក្នុងដំណាំស្រូវរដូវវស្សាមានរំហួតពីផ្ទៃទឹកជាមធ្យម៣,៧មម/ថ្ងៃ និងដោយដំណកដង្ហើម១,៤ម ម/ថ្ងៃ (ក្រាហ្វិក៣)។




ក្រាហ្វិក៣. រំហួតបរិយាកាស (Pan evaporation) និងរំហួតពីផ្ទៃទឹក (Evaporation) ព្រមទាំងរំហួតដោយដំណកដង្ហើម (Transpiration) របស់ដំណាំស្រូវក្នុងរដូវប្រាំងនិងវស្សាគិតជា មម ក្នុងមួយថ្ងៃ (y, mm)




ក្រាហ្វិក៤. ភាគរយកូនមមាចញ្ញាស់ (អ័ក្ស y, Hatching) បន្ទាប់ពន្លិចទឹកពី២ ទៅ១៤ថ្ងៃ (អ័ក្ស x, day) និងភាគរយកូនមមាចឆ្អោតដែលញាស់ហើយនៅរស់បន្ទាប់ពីបង្ហូរទឹករយៈពេល៦ថ្ងៃ (អ័ក្ស y, Surviving)



Cambodian Agricultural Research and Development Institute

ង.៣.៣. វិធីសាស្រ្តកាត់បន្ថយមមាចត្នោតៈលទ្ធផលនៃពិសោធន៍២ឆ្នាំកន្លងមកនេះបានបញ្ជាក់ថា ការពន្លិចទឹកដំណាំស្រូវនៅដំណាក់កាលសំណាបទៅបែកគុម្ពឲ្យលិចពាក់កណ្តាលស្លឹកក្នុងរយៈពេលពី៦–១០ថ្ងៃ ជាវិធានការដ៏ល្អមួយក្នុងការកាត់បន្ថយកូនញាស់របស់មមាចត្នោតនិងអត្រារស់របស់វា។ ក្នុងករណីនេះ អត្រាកូនញាស់បានធ្លាក់ចុះដល់៥៨% (៦ថ្ងៃ) ២០% (១០ថ្ងៃ) និង១៨% (១៤ថ្ងៃ) ដែលជាមធ្យមថយចុះ៥,៥%ក្នុងមួយថ្ងៃ ហើយភាគរយកូនញាស់ដែលនៅរស់ បន្ទាប់ពីបង្ហូរទឹកបាន៦ថ្ងៃ ធ្លាក់ចុះដល់៤២% (៦ថ្ងៃ) ៣៣% (១០ថ្ងៃ) និង២៥% (១៤ថ្ងៃ) ដែលជាមធ្យមថយចុះ២,៩%ក្នុងមួយថ្ងៃ (ក្រាហ្វិក៤)។

ង.៣.៤. ថ្នាំពុលកម្ចាត់មមាចត្នោតៈ តាមលទ្ធផលពិសោធន៍ថ្នាំពុលកសិកម្ម៤ប្រភេទបានបង្ហាញថា ថ្នាំ APATA មានប្រសិទ្ធភាពខ្ពស់ជាងគេក្នុងការកម្ចាត់ទាំងមេមមាច (៩៣%) និងទាំងជួយកាត់បន្ថយអត្រាពងញាស់បានច្រើនប្រហាក់ប្រហែលនឹងការប្រើថ្នាំ Dinotefuran ដែរ (ក្រាហ្វិក៥)។ ការប្រើប្រាស់ថ្នាំនេះ ត្រូវផ្លាស់ប្តូរជាមួយថ្នាំ OSHIN20WP ម្តងម្កាលផងដែរ ដើម្បីរក្សាប្រសិទ្ធភាពនៃថ្នាំ និងជួយកាត់បន្ថយភាពធន់របស់សត្វល្អិតទៅលើថ្នាំ។




ក្រាហ្វិក៥. ប្រសិទ្ធភាពរបស់ថ្នាំកសិកម្មដែលមានលក់នៅលើទីផ្សារទៅលើមមាចនិងពងញាស់ (y, %), (LSD5% អត្រាមមាចងាប់=៨ និងអត្រាពងញាស់=៥)

ង.៣.៥. ការកម្ចាត់ខ្យងពណ៌មាសៈ លទ្ធផលពិសោធន៍បានបង្ហាញថា ក្រៅពីប្រើថ្នាំនុយ Mollucide6GB នៅមានថ្នាំមួយប្រភេទទៀតគឺ Osbuvang5G ដែលមានប្រសិទ្ធភាពដូចថ្នាំ Mollucide6GB ផងដែរ (ក្រាហ្វិក៦)។




ក្រាហ្វិក៦. ឥទ្ធិពលនៃថ្នាំសម្លាប់ខ្យងបីប្រភេទទៅលើខ្យង (Golden apple snail) និងត្រី កំពិស ក្តាម (Fish, shrimp and crab), (y, %)

ការប្រើថ្នាំទាំងពីរប្រភេទនេះតាមកម្រិតណែនាំ គឺ១០គ.ក្រ Mollucide6GB (ប្រហែល១សែនរៀល) ឬ៥គក្រ/ហត Osbuvang5G (ប្រហែល៥ម៉ឺនរៀល) មិនបណ្តាលឲ្យងាប់ត្រី កំពិស និងក្តាមនៅក្នុងស្រែឡើយ។ ថ្វីត្បិតតែការ

Cambodian Agricultural Research and Development Institute

ប្រើប្រាស់ថ្នាំ Osbuvang5G ចំណាយតិច តែកសិករត្រូវតែប្រើប្រាស់ថ្នាំនុយទាំងពីរប្រភេទនេះឆ្លាស់គ្នា ជៀសវាងការបន្សាំបានរបស់ខ្យង។ សូមកុំប្រើថ្នាំ Snailicide700wp ឲ្យសោះ ពីព្រោះវាពុលខ្លាំងដល់ត្រី កំពិស និងក្តាមនៅក្នុងស្រែ។

**ង.៣.៦. សមាសភាពចង្រៃលើដំណាំស្រូវវស្សា៖** លទ្ធផលនៃការចុះសិក្សាក្នុងស្រែចំនួន៦៤នៅខេត្តតាកែវ កំពង់ធំ បាត់ដំបង និងព្រៃវែងនៅបីដំណាក់កាលបានបង្ហាញជារួមថា ដំណាំស្រូវត្រូវបានបំផ្លាញដោយកណ្តុរ៥,២% ខ្យងស៊ីជាលិកាស្លឹកស្រូវ៥,៤% ស្រូវមានជំងឺរលាកគែមស្លឹកដោយបាក់តេរី២,៨% អុចត្នោត៦,៨% ឆ្នូតត្នោត១១,៦% ខ្នារអំបោះស្លឹក០,២% និងខ្នារអំបោះកក្បូរ០,៧% ព្រមទាំងស្មៅដុះខ្ពស់ជាងស្រូវមាន៣០% និងទាបជាងស្រូវមាន៣៤%។

**ង.៣.៧. បង្កើតបាននូវផែនទីក្រុមដីស្រែនៃអនុប្រព័ន្ធស្រោចស្រពចំនួន១០៖** បានចុះសិក្សា វាយតម្លៃ និងបង្កើតផែនទីក្រុមដីស្រែក្នុងអនុប្រព័ន្ធស្រោចស្រពបានចំនួន១០ ដោយក្នុងនោះនៅខេត្តព្រៃវែងចំនួន១ (អនុប្រព័ន្ធស្រោចស្រពប្រមូលដុំ) ខេត្តស្វាយរៀងចំនួន២ (អនុប្រព័ន្ធស្រោចស្រពចំបក់ និងតាស្មាង) ខេត្តកំពង់ចាមចំនួន២ (អនុប្រព័ន្ធស្រោចស្រពបឹងកក់និងវាលធំ) ខេត្តក្រចេះចំនួន២ (អនុប្រព័ន្ធស្រោចស្រពតាសេងនិងព្រែកថ្លុង) ខេត្តមណ្ឌលគីរីចំនួន១ (អនុប្រព័ន្ធស្រោចស្រពអូរប្រាង) ខេត្តរតនគីរីចំនួន១ (អនុប្រព័ន្ធស្រោចស្រពត្រពាំងច្រេះ) និងខេត្តស្ទឹងត្រែងចំនួន១ (អនុប្រព័ន្ធស្រោចស្រពបាចុង)។

**ង.៣.៨. បង្កើតបាននូវផែនទីក្រុមដីនិងសណ្ឋានដីចំនួនពីរ៖** បានចុះសិក្សាវាយតម្លៃដី ដោយបានធ្វើការពណ៌នាទាំងសង្ខេបនិងលម្អិតនៅខេត្តប៉ៃលិនបានចំនួន២២ប្រូហ្វីល និងនៅស្រុកសំឡូតនៃខេត្តបាត់ដំបងបានចំនួន១៦ប្រូហ្វីល ព្រមទាំងបានបង្កើតនូវផែនទីក្រុមដីនិងសណ្ឋានដីរបស់ខេត្តប៉ៃលិននិងស្រុកសំឡូត។ ព័ត៌មានទាំងឡាយនៃការអង្កេតនេះ ត្រូវបានបញ្ចូលនិងរក្សាទុកក្នុងប្រព័ន្ធទិន្នន័យគ្រឹះដីរបស់វិទ្យាស្ថានកាឌី។

**ង.៣.៩. ប្រព័ន្ធដាំដុះដំណាំស្រូវក្នុងតំបន់ស្រោចស្រពពេញលេញ:** លទ្ធផលពិសោធន៍រយៈពេល៣ឆ្នាំលើដីប្រទះឡាងបានបង្ហាញថា ជាមធ្យមក្នុងមួយឆ្នាំ (១)កសិករអាចដាំដុះដំណាំស្រូវបាន៣ដង ដោយប្រើពូជស្រូវជលសារ (ឬពូជស្រូវ




ក្រាហ្វិក៧. បរិមាណផលស្រូវមធ្យម៣ឆ្នាំ (PY) ទុនចំណាយ (Input) ប្រាក់ចំណូល (Income) និងប្រាក់ចំណេញដុល (GM) (y) របស់ប្រព័ន្ធដាំដុះ ១)ស្រូវប្រាំង+ដើមរដូវវស្សា (DS+EWS) ២)ស្រូវប្រាំង+ស្រូវវស្សា (DS+WS) ៣)ស្រូវដើមរដូវវស្សា+ស្រូវវស្សា (EWS+WS) និង៤)ស្រូវប្រាំង+ស្រូវដើមរដូវវស្សា+ស្រូវវស្សា (DS+EWS+WS)

Cambodian Agricultural Research and Development Institute

មានអាយុកាលខ្លីជាង១០០ថ្ងៃ) សម្រាប់ស្រូវប្រាំង (DS) និងស្រូវដើមរដូវវស្សា (EWS) និងពូជស្រូវផ្ការំដួល (ឬពូជស្រូវក្រអូបចេញផ្កាដំណាល) សម្រាប់រដូវវស្សា (WS) (២)ការដាំដុះដំណាំស្រូវ២ឬ៣ដង/ឆ្នាំដោយរៀបចំដី និងប្រើប្រាស់ជីសមស្រប មិនបណ្តាលឲ្យផលិតភាពដីធ្លាក់ចុះទេ (៣)ការដាំដុះដំណាំស្រូវ៣ដង/ឆ្នាំ (DS+EWS+WS) បង្កើនបរិមាណផលស្រូវក្នុងផ្ទៃដី១ហិកតាដល់១១,៨តោន និងប្រាក់ចំណេញដុល១.៣៤០ដុល្លារ និង (៤)ការដាំដុះដំណាំស្រូវដើមរដូវវស្សានិងរដូវវស្សា (EWS+WS) ផ្តល់បរិមាណផល៧,៧តោន និងប្រាក់ចំណេញដុល ១,០៧០ដុល្លារ ហើយក៏ជាប្រព័ន្ធដាំដុះដែលមានអត្រាវិនិយោគល្អជាងប្រព័ន្ធដាំដុះដទៃទៀត ព្រមទាំងអនុញ្ញាតឲ្យកសិករអាចដាំដុះដំណាំបន្លែ ឬសណ្តែកបាយក្នុងរដូវប្រាំង (ក្រាហ្វិក៧)។

ង.៣.១០. ឧបករណ៍ដាំបង្កប់គ្រាប់ពូជស្រូវ៖ ឧបករណ៍នេះត្រូវបានកែច្នៃឲ្យបានសមស្របតាមលក្ខខណ្ឌប្រទេសកម្ពុជា ហើយលទ្ធផលដែលទទួលបានពីការសាកល្បងរបស់កសិករចំនួន២៣នាក់បានបង្ហាញថា ទិន្នផលស្រូវដាំដោយឧបករណ៍នេះ ជាមធ្យមមាន៣,២៥ត/ហត ខ្ពស់ជាងការព្រោះដោយដៃប្រមាណ០,៤៥ត/ហត។ ក្រៅពីផ្តល់ទិន្នផលខ្ពស់ដោយសារស្រូវដុះលូតលាស់បានល្អនិងស្មើគ្នាជាជួរស្រួលដើរថែទាំ ឧបករណ៍នេះ ក៏ជួយកាត់បន្ថយបរិមាណគ្រាប់ពូជពី១២០–១៥០គក្រ/ហតមក៦០–៨០គក្រ/ហតផងដែរ។

ង.៣.១១. ការប្រើប្រាស់គ្រឿងយន្តក្នុងដំណាំស្រូវ៖ លទ្ធផលសម្ភាសន៍ជាមួយកសិករក្នុងខេត្តចំនួន៨បានបង្ហាញថា ក្នុងការរៀបចំដីស្រែ មានកសិករប្រមាណ១៧%នៅប្រើប្រាស់គោក្របី ៦១%ប្រើប្រាស់គោយន្ត និង២២%ប្រើប្រាស់ត្រាក់ទ័រ (ក្រាហ្វិក៨)។ មូលហេតុសំខាន់របស់កសិករដែលនៅប្រើប្រាស់គោក្របីគឺ ក.អត់មានលទ្ធភាពទិញឬជួល (៣១%) ខ.ដីស្រែមានទំហំតូចពេក (២១%) គ.ចង់បានជីលាមកសត្វដាក់ដំណាំ (១៣%) និង ឃ.ផ្សេងៗទៀត (៣៦%) (ក្រាហ្វិក៨)។ ដោយឡែកចំពោះការច្រូតកាត់វិញ មានកសិករដែលច្រូតកាត់ដោយដៃក្នុងស្រែប្រាំងប្រមាណ១០% ស្រែដើមរដូវវស្សាប្រមាណ១៩% និងស្រែវស្សាប្រមាណ៤២% (ក្រាហ្វិក៩)។







ក្រាហ្វិក៨. ការប្រើប្រាស់មធ្យោបាយរៀបចំដីស្រែ (y, %) ក្រាហ្វិក៩. ការប្រើប្រាស់មធ្យោបាយប្រមូលផលស្រូវ (y, %)

កសិករដែលប្រើម៉ាស៊ីនច្រូតផ្តួលដើមក្នុងស្រែដើមរដូវវស្សាមានច្រើនជាងគេ (១៦%) ស្រែប្រាំង (១១%) និងស្រែវស្សាតិចជាងគេ (៧%)។ ម៉ាស៊ីនច្រូតកាត់ដោយម៉ាស៊ីនកុំបៃមានការពេញនិយមខ្លាំង គឺរហូតដល់៨០%ចំពោះស្រែប្រាំង ៦៤%ចំពោះស្រែដើមរដូវវស្សា និង៥១%ចំពោះស្រូវវស្សា។ តម្លៃឈ្នួលច្រូតកាត់ដោយម៉ាស៊ីនកុំបៃប្រែប្រួលពី២សែនរៀលទៅដល់៦សែនរៀល/ហត ទៅតាមស្ថានភាពស្រូវ និងជាមធ្យមសម្រាប់ស្រូវប្រាំងនិងស្រូវដើមរដូវវស្សាគឺ២,៥សែនរៀល និងស្រូវវស្សាគឺ៣,៥សែនរៀល/ហត។

Cambodian Agricultural Research and Development Institute

ង.៣.១២. ប្រាក់ចំណេញរបស់ម្ចាស់ម៉ាស៊ីនកុំបៃ៖ លទ្ធផលសិក្សានៅខេត្តតាកែវ កំពត និងកំពង់ស្ពឺបង្ហាញថា ម្ចាស់ម៉ាស៊ីនកុំបៃបានយកប្រាក់ច្រូតស្រូវវស្សាជាមធ្យម១១០ដុល្លារ/ហត និងស្រូវប្រាំង៧០ដុល្លារ/ហត។ ដោយឡែកក្នុងរដូវវស្សា ម្ចាស់ម៉ាស៊ីនកុំបៃបានរកលុយចំណេញប្រចាំថ្ងៃប្រមាណ២២៥ដុល្លារចំពោះស្រែទំហំតូច (៥–១០អា) ដោយច្រូតបានជាមធ្យម៣ហត/ថ្ងៃ និង៣៦៦ដុល្លារចំពោះស្រែទំហំធំ (២០–៣០អា) ដោយច្រូតបានជាមធ្យម ៤,៥ហត/ថ្ងៃ។

ង.៣.១៣. ការប្រើប្រាស់ជីលើដំណាំស្រូវ៖ លទ្ធផលនៃការអង្កេតនៅក្នុងខេត្តទាំង១២ខាងលើ ក៏បានបង្ហាញផងដែរថា (១)មានកសិករតែ១២,៥%ប៉ុណ្ណោះដែលមិនប្រើប្រាស់ជីកសិកម្មគ្រប់ប្រភេទ (២)មានកសិករប្រមាណ០,៥% ដែលប្រើប្រាស់ជីសរីរាង្គសុទ្ធ (OF) លើស្រូវប្រាំង (Dry season) ដើមរដូវវស្សា (Early wet season) និងវស្សា (Wet season) (៣)កសិករដែលប្រើប្រាស់ជីគីមី (CF) សុទ្ធមាន៩៤,៥%លើស្រូវប្រាំង ៤៦,៩%លើស្រូវដើមរដូវវស្សា និង៧៣,៨%លើស្រូវវស្សា និង(៤)មានកសិករប្រើប្រាស់ជីគីមីលាយជាមួយជីសរីរាង្គ (OF+CF) ចំនួន៤,៦%លើស្រូវប្រាំង ៥២%លើស្រូវដើមរដូវវស្សា និង១៩,៣%លើស្រូវវស្សា (ក្រាហ្វិក១០)។




ក្រាហ្វិក១០. ការប្រើប្រាស់ជីលើដំណាំស្រូវតាមរដូវកាល (y, %)

## ង.៤. ការងារស្រាវជ្រាវលើដំណាំដំឡូងមី

ង.៤.១. ការហូរច្រោះដីដោយដំណាំដំឡូងមី៖ លទ្ធផលសរុបរយៈពេល២ឆ្នាំលើក្រុមដីកំពង់សៀមនៃចម្ការកសិករចំនួន ៣កន្លែង ក្នុងលក្ខខណ្ឌដី អាកាសធាតុ និងការអនុវត្តជាក់ស្តែងរបស់កសិករក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបងបានបង្ហាញជាបឋមថា ការដាំដំឡូងមីនៅលើដីចម្ការដែលមានជម្រាលដី៤–៧% បានបណ្តាលឲ្យបាត់បង់ដីស្រទាប់លើ (ម៉ាសស្ងួត) សរុបប្រមាណ៦០–១៨០ត/ហត ដែលសមាមាត្រទៅនឹងកម្រាស់ដីពី៤,៣–៨,៥មម។ តួលេខនេះបញ្ជាក់ថា ការហូរច្រោះដីមានកម្រិតមធ្យម។



រូបភាព១៤. ការរៀបចំដីកប្រឡាយនិងដាក់ប្លាស្ទិកត្រងយកដីហូរច្រោះនៅចម្ការដំឡូងមីរបស់កសិករ



Cambodian Agricultural Research and Development Institute

ង.៤.២. ការប្រែប្រួលលក្ខណៈរូបនិងគីមីនៃដីដាំដុះដំឡូងមី៖ លទ្ធផលមធ្យមនៃពិសោធន៍ចំនួន៣កន្លែងក្នុងរយៈពីរឆ្នាំជាប់ៗគ្នាលើក្រុមដីកំពង់សៀមបានបង្ហាញថា លក្ខណៈរូបនិងគីមីនៃដី (Soil properties) មិនមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ទេ លើកលែងតែបណ្ដូរកាចុង (Exchangeable) $Ca^{2+}$ និង $Mg^{2+}$ ព្រមទាំងបរិមាណដីល្បាប់ (Silt) ដែលមានការថយចុះ ទោះក្នុងករណីមិនដាក់ជី និងដាក់ជីទាំងកម្រិតទាបឬខ្ពស់ក៏ដោយ (តារាង៤)។

តារាង៤. លក្ខណៈរូបនិងគីមីនៃដី (Soil properties) មុនពេលដាំ (Before planting) ក្រោយដាំឆ្នាំទីមួយ និងទីពីរ ក្នុងកម្រិតមិនប្រើប្រាស់ជី (Nil) ប្រើប្រាស់ជីកម្រិតទាប (40:20:40) និងកម្រិតខ្ពស់ (160:80:100)

| Soil properties | Before planting | Year 1: $N:P_2O_5:K_2O$ (kg/ha) | | | Year 2: $N:P_2O_5:K_2O$ (kg/ha) | | |
|---|---|---|---|---|---|---|---|
| | | Nil | 40:20:40 | 160:80:100 | Nil | 40:20:40 | 160:80:100 |
| pH-H2O (1:5) | 8.07 | 0.23 | 0.20 | 0.20 | -0.48 | -0.41 | -0.40 |
| EC (mS/cm) | 0.31 | -0.07 | -0.06 | -0.06 | -0.20 | -0.20 | -0.11 |
| Organic C (%) | 0.94 | 0.27 | 0.62 | 0.56 | 0.95 | 0.93 | 0.94 |
| Total N (%) | 0.12 | -0.02 | -0.02 | -0.02 | 0.08 | 0.09 | 0.07 |
| Available P (mg/kg) | 3.43 | 1.86 | 3.58 | 4.34 | 6.50 | 10.54 | 9.67 |
| Exchangeable $Ca^{2+}$ (cmol/kg) | 21.10 | 7.77 | 5.30 | 6.00 | -10.54 | -11.02 | -10.73 |
| Exchangeable $Mg^{2+}$(cmol/kg) | 2.20 | -0.78 | -1.40 | -1.28 | -1.65 | -1.67 | -1.67 |
| Exchangeable $K^{+}$(cmol/kg) | 0.48 | 0.01 | 0.02 | -0.05 | -0.01 | 0.06 | 0.05 |
| Exchangeable $Na^{+}$(cmol/kg) | 0.10 | -0.03 | -0.03 | -0.02 | -0.02 | -0.02 | -0.03 |
| Sand (%) | 29 | 4 | 3 | 3 | 3 | 1 | 1 |
| Silt (%) | 31 | -4 | -2 | -2 | -2 | -2 | -2 |
| Clay (%) | 41 | 0 | -1 | -1 | -1 | 2 | 1 |
| Fresh root yield (t/ha) | | 27 | 32 | 33 | 28 | 34 | 40 |

ង.៤.៣. ការស្រូបយកសារធាតុចិញ្ចឹមរបស់ដំឡូងមី៖ លទ្ធផលពិសោធន៍ចំនួន៣កន្លែងលើក្រុមដីកំពង់សៀមនៅក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបងរយៈពេល២ឆ្នាំបញ្ចូលគ្នាបានបង្ហាញថា ជាមធ្យមការដាក់ជីគីមី ($N:P_2O_5:K_2O$) កម្រិតទាប (40:20:40) បង្កើននូវផលដំឡូងមីសើមទាំងដើមនិងមើមប្រមាណ១០ត/ហត ហើយផលនេះកើនដល់ជាង២០ត/ហតចំពោះជីគីមីកម្រិតខ្ពស់ (160:80:100) ធៀបទៅនឹងការមិនដាក់ជីដែលផ្ដល់ផលតែជិត៥៥ត/ហតប៉ុណ្ណោះ (តារាង៥)។ បរិមាណសារធាតុចិញ្ចឹម (N, P, K, Ca និង Mg) មិនមានការប្រែប្រួលសំខាន់ទេរវាងជីកម្រិតទាបនិងមិនដាក់ តែចំពោះការដាក់ជីកម្រិតខ្ពស់វិញ ដំណាំដំឡូងមីស្រូបយកសារធាតុចិញ្ចឹមខ្ពស់ជាងមិនដាក់ជី លើកលែងតែ Ca ប៉ុណ្ណោះ។

តារាង៥. ផលដំឡូងមីសើមទាំងដើមនិងមើមសរុបរយៈពេល២ឆ្នាំ (ត/ហត) និងបរិមាណសារធាតុចិញ្ចឹម (N, P, K, Ca និង Mg) ដែលស្រូបយក (គក្រ/ហត) ក្នុងលក្ខខណ្ឌមិនដាក់ជី (Nil) ដាក់ជីកម្រិតទាប (40:20:40) និងកម្រិតខ្ពស់ (160:80:100) នៃ ($N:P_2O_5:K_2O$)

| $N:P_2O_5:K_2O$ (kg/ha) | Total biomass (t/ha) | N | P | K | Ca | Mg |
|---|---|---|---|---|---|---|
| Nil | 54.66 | 16.39 | 3.05 | 10.42 | 10.33 | 2.43 |
| 40:20:40 | 65.84 | 16.89 | 2.94 | 9.16 | 9.74 | 2.04 |
| 160:80:100 | 75.03 | 22.01 | 3.42 | 8.76 | 11.16 | 2.47 |

ង.៤.៤. ការប្រែប្រួលនៃផ្ទៃដីនិងទិន្នផលដំឡូងមី៖ ជាទូទៅ ផ្ទៃដីដាំដុះដំឡូងមីក្នុង១គ្រួសារនៅខេត្តប៉ៃលិនមានការថយចុះពី៤,០ហតក្នុងឆ្នាំ២០១០ មក៣,៧ហតក្នុងឆ្នាំ២០១៣ ហើយក៏ដូចគ្នាដែរចំពោះខេត្តកំពង់ចាម គឺថយពី

Cambodian Agricultural Research and Development Institute

១,៣៣ហតក្នុងឆ្នាំ២០១០ មក១,២៨ហតក្នុងឆ្នាំ២០១៣។ ទិន្នផលដំឡូងមីនៅខេត្តប៉ៃលិនក្នុងឆ្នាំ២០១៣ មានប្រមាណ២៩ត/ហត ថយចុះជាងឆ្នាំ២០១០ប្រមាណ១៥ត/ហត និងខេត្តកំពង់ចាមថយចុះប្រមាណ៥ត/ហត (ទិន្នផលឆ្នាំ២០១៣មានប្រមាណ២០ត/ហត)។ ផ្ទុយទៅវិញ តម្លៃដំឡូងស្រស់មានការកើនឡើងខ្លាំងនៅខេត្តប៉ៃលិនគឺពី១៨៦រៀល/គក្រក្នុងឆ្នាំ២០១០ ទៅ២៥០រៀល/គក្រក្នុងឆ្នាំ២០១៣ ហើយខេត្តកំពង់ចាមមានការកើនឡើងតែបន្តិច គឺប្រមាណ៥០រៀល/គក្រ (ឆ្នាំ២០១៣ ថ្លៃប្រមាណ៣០០រៀល/គក្រ)។

## ង.៥. ការងារស្រាវជ្រាវលើពិពិធកម្មដំណាំលើដីស្រែទំនាបរំពឹងទឹកភ្លៀង

ង.៥.១. ឥទ្ធិពលនៃសំណើមដីទៅលើដំណុះនាពនៃដំណាំសណ្តែកដី សណ្តែកបាយ ពោត និងស្រូវបន្ទាប់ពីប្រមូលផលស្រូវវស្សា៖ តាមលទ្ធផលនៃការសិក្សា ការដាំដុះរាល់ដំណាំខាងលើទទួលបានអត្រាដំណុះច្រើនក្នុងការដាំដុះនៅជម្រៅពី៥-៦សម ទោះបីជាការដាំដុះនោះធ្វើឡើងដោយម៉ាស៊ីនឬដៃក៏ដោយ។ នៅលើក្រុមដីប្រទះឡាង ដែលមានសមត្ថភាពរក្សាទឹកទាប ការដាំដុះក្នុងកម្រិតសំណើម២៥%ទទួលបានអត្រាដំណុះខ្ពស់ ប៉ុន្តែក្នុងកម្រិតសំណើម១២% ការដុះរបស់ដំណាំមានកម្រិតទាបពិសេសដំណាំស្រូវ (ក្រាហ្វិក១១)។ ក្នុងចំណោមដំណាំទាំង៤ សណ្តែកដីជាដំណាំដែលទទួលបានដំណុះខ្ពស់ ដោយឡែកដំណាំស្រូវពុំមានដំណុះល្អទេ បើកាលណាធ្វើការដាំដុះលើដីដែលមានសំណើមទាប។




ក្រាហ្វិក១១. ឥទ្ធិពលនៃសំណើមដីទៅលើដំណុះភាពនៃដំណាំសណ្តែកដី សណ្តែកបាយ ពោត និងស្រូវ

ង.៥.២. ប្រសិទ្ធភាពនៃការបំបែកស្រទាប់បាតនង្គ័ល៖ ការបំបែកស្រទាប់បាតនង្គ័លរបស់ក្រុមដីប្រទះឡាងបន្ទាប់ពីប្រមូលផលស្រូវវស្សា បង្កើននូវទិន្នផលពោតដល់ទៅ៤,៦ត/ហត ខ្ពស់ជាងមិនបំបែកស្រទាប់បាតនង្គ័ល២០% ទន្ទឹមនឹងបង្កើនប្រសិទ្ធភាពប្រើប្រាស់ទឹក០,៥គក្រ/ម៣ ព្រមទាំងបង្កើនទិន្នផលសណ្តែកដីប្រមាណ៣០% និងប្រសិទ្ធភាពប្រើប្រាស់ទឹក០,១គក្រ/ម៣។

## ង.៦. ការងារស្រាវជ្រាវលើដំណាំផ្សេងទៀត

ង.៦.១. ពិសោធន៍ស្តីពីប្រសិទ្ធភាពជី NPK លើទិន្នផលស្វាយកែវរមៀត៖ ពិសោធន៍ទើបចាប់ផ្តើមធ្វើនៅចម្ការស្វាយកែវរមៀតមួយកន្លែងក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ លទ្ធផលបឋមបានបង្ហាញថា ការដាក់ជី NPK បន្ថែមចំនួន១–២គក្រ/ដើម កើនទិន្នផលផ្លែជិតពីរដងធៀបទៅនឹងដើមដែលមិនបានដាក់ជី ដែលផ្តល់ផលតែ១០គក្រ/ដើម។

Cambodian Agricultural Research and Development Institute

ង.៦.២. សមាសភាពចង្រៃលើដំណាំស្វាយ៖ លទ្ធផលបឋមនៃការសិក្សាដើម្បីកំណត់រកសមាសភាពសត្វល្អិតចង្រៃសំខាន់ៗបំផ្លាញដំណាំស្វាយនាដំណាក់កាលផ្សេងៗក្នុងខេត្តកំពង់ចាម កំពង់ស្ពឺ កណ្ដាល សៀមរាប និងបាត់ដំបងបានបង្ហាញថា ដង្កូវចោះផ្លែនិងរុយផ្លែមានវត្តមានច្រើនជាងគេចាប់ពីដំណាក់កាលចេញផ្លែរហូតដល់ទុំ។ ចំណែកជំងឺវិញមាន Anthracnose, leaf spot និង fruit rot។

ង.៦.៣. ប្រភពប៉េងប៉ោះនិងស្ពៃក្តោបលក់នៅទីផ្សារ៖ ប៉េងប៉ោះភាគច្រើនដែលលក់នៅផ្សារច្បារអំពៅ ផ្សារដើមគរ និងផ្សារនាគមាសក្នុងរាជធានីភ្នំពេញមានប្រភពមកពីប្រទេសវៀតណាម៨៨% ថៃ៥% និងក្នុងស្រុក៧% និងផ្សារសាមគ្គីក្រុងសៀមរាប មានប្រភពមកពីប្រទេសវៀតណាម៩៦% និងក្នុងស្រុក៤%។ ផ្ទុយទៅវិញចំពោះប្រភពស្ពៃក្តោបភាគច្រើនដែលលក់នៅផ្សារទាំងបីក្នុងរាជធានីភ្នំពេញមានប្រភពមកពីក្នុងស្រុក៨៥% និងប្រទេសវៀតណាម១៥% និងផ្សារសាមគ្គីក្រុងសៀមរាបមកពីប្រភពក្នុងស្រុក៩២% និងថៃ៨%។

ង.៦.៤. ការបាត់បង់ក្រោយពេលប្រមូលផលរបស់បន្លែស្ពៃក្តោប៖ លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ពៃក្តោបដែលកសិករដាំនៅស្រុកស្អាងនិងដឹកមកលក់ឲ្យអ្នកប្រមូលទិញក្នុងស្រុក ហើយអ្នកប្រមូលទិញក្នុងស្រុកយកមកលក់បន្តឲ្យអ្នកប្រមូលទិញនៅផ្សារនាគមាស និងជាចុងក្រោយបន្តដឹកយកទៅលក់ដល់ទីផ្សារខេត្តសៀមរាប ត្រូវបានរលួយខូចអស់ប្រមាណ៣០% និងស្រកទម្ងន់អស់២,៥%។

## ង.៧. ការផ្សព្វផ្សាយ ការផ្ទេរបច្ចេកវិទ្យា និងបណ្តុះបណ្តាលធនធានមនុស្ស

ង.៧.១. ផលិតកម្មគ្រាប់ពូជស្រូវ៖ នាឱកាសទស្សនាពិព័រណ៍របស់ក្រសួងក្នុងទិវាស្រូវ–អង្ករ រៀបចំដោយសហព័ន្ធស្រូវ–អង្ករកម្ពុជា ដែលប្រារព្ធនៅអូតែលសុខានាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់ថា ដើម្បីធានានូវភាពសុទ្ធរបស់ពូជស្រូវដែលក្រសួងបានបញ្ចេញ វិទ្យាស្ថានកាឌីត្រូវតែបន្តផលិតគ្រាប់ពូជគ្រឹះផ្គត់ផ្គង់ជូនអតិថិជនឲ្យផលិតគ្រាប់ពូជចំណាត់ថ្នាក់បន្តបន្ទាប់ទៀត ផ្គត់ផ្គង់ជូនកសិករដាំដុះ។

រាល់ពូជដំណាំដែលវិទ្យាស្ថានបានបញ្ចេញជូនកសិករប្រើប្រាស់ត្រូវបានធានានូវភាពសុទ្ធ តាមរយៈការផលិតគ្រាប់ពូជគ្រឹះ គ្រាប់ពូជអនុញ្ញាត្ត និងគ្រាប់ពូជសុទ្ធល្អ ផ្គត់ផ្គង់តាមការបញ្ជាទិញរបស់ក្រុមហ៊ុនឯកជន សហគមន៍កសិកម្ម និងគម្រោងអភិវឌ្ឍន៍នានាដែលអនុវត្តដោយអង្គភាពជំនាញរបស់ក្រសួងនិងអង្គការផ្សេងៗ ដើម្បីផលិតនិងផ្គត់ផ្គង់បន្តជូនកសិករ។ ក្នុងបីឆ្នាំនេះ គ្រាប់ពូជស្រូវប្រមាណ២៩៧តោនបានផលិត ដោយក្នុងនោះ ប្រមាណ១១៤តោនផលិតដោយវិទ្យាស្ថានកាឌី និងប្រមាណ១៨៣តោនផលិតដោយកសិករសហការ តាមរយៈការបញ្ជ្រាបបង្កបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវវស្សា។ បានផ្តល់គ្រាប់ពូជគ្រឹះរបស់ពូជស្រូវស្មាច់០២ ជូនកសិករ៤០គ្រួសារក្នុងសហគមន៍កសិកម្មស្រូវស្មាច់កំពង់រោទិ៍ចំនួន២០០គក្រ និងបានចែកគ្រាប់ពូជស្រូវគ្រឹះជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ នូវពូជដំណើបស្បៃមង្គលចំនួន១៥គក្រ/មន្ទីរ និងពូជផ្ការំដួលប្រាំងចំនួន៣០គក្រ/មន្ទីរ ព្រមទាំងនាយកដ្ឋានដំណាំស្រូវ (ដំណើបស្បៃមង្គល=ពូជផ្ការំដួលប្រាំង=៤០គក្រ) ដើម្បីផលិតផ្សព្វផ្សាយជូនកសិករ និងបានជូនគ្រាប់ពូជគ្រឹះរបស់ពូជស្រូវដំណើបស្បៃមង្គលដល់សហគមន៍ក្រឡានថ្មគ្រែនៅខេត្តក្រចេះចំនួន១០០គ.ក្រ។

ង.៧.២. បង្កបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សានៅតំបន់ឆ្នេរ៖ យោងតាមលទ្ធផលស្រែបង្ហាញចំនួន៨២កន្លែង ដែលបានអនុវត្តក្នុងរយៈពេល៤ឆ្នាំ នៅតំបន់ទំនាបឆ្នេរដែលទទួលរងឥទ្ធិពលទឹកប្រៃក្នុងខេត្តព្រះសីហនុនិងកែប បាន

Cambodian Agricultural Research and Development Institute

បង្ហាញថា (១)ពូជស្រូវផ្ការំដួល ផ្ការមៀត និងផ្ការំដេង ដែលជាពូជស្រូវមានគុណភាពល្អនិងមានទីផ្សារ ដុះលូតលាស់បានល្អដោយផ្តល់ផល៣,០៤ត/ហាត ធៀបនឹងពូជស្រូវរបស់កសិករ(២,៨៣ត/ហាត) ធ្វើឲ្យកសិករទទួលបានប្រាក់ចំណេញ០,៩៤លានរៀលបន្ថែមពីលើការប្រើប្រាស់ពូជរបស់ខ្លួន (០,៩៨លានរៀល) និង(២)ការអនុវត្តតាមបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ បានបង្កើនទិន្នផលស្រូវរហូតដល់៣,៤៦ត/ហាតលើសពីទម្លាប់កសិករ០,៦៣ត/ហាត និងទទួលបានប្រាក់ចំណេញដុលខ្ពស់រហូតដល់២,១៨លានរៀលលើសពីការប្រើប្រាស់តាមទម្លាប់របស់កសិកររហូតដល់១,២លានរៀល/ហាត (ក្រាហ្វិក១២ ឆ្វេង)។




ក្រាហ្វិក១២. បង្គុំបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សានៅតំបន់ឆ្នេរ (ឆ្វេង) និងបង្គុំបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សា (ស្តាំ) (y).

**ង.៧.៣. បង្គុំបច្ចេកទេសបង្កើនផលិតភាពស្រូវវស្សា៖** យោងតាមលទ្ធផលស្រែបង្ហាញចំនួន២២៣កន្លែង ដែលបានអនុវត្តក្នុងរយៈពេល៥ឆ្នាំ បានបង្ហាញថា (១)ការជំនួសពូជស្រូវកសិករដោយពូជទាំង១០ពូជតាមលក្ខខណ្ឌដាំដុះ បានបង្កើនទិន្នផលពី២,៤៩ត/ហាត ទៅ៣,០៧ត/ហាត និងទទួលបានប្រាក់ចំណេញដុល០,៦២លានរៀលខ្ពស់ជាងការប្រើប្រាស់ពូជកសិករ (១,២៦លានរៀល) និង(២)ការអនុវត្តន៍តាមបង្គុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ បានបង្កើនទិន្នផលស្រូវរហូតដល់៣,៨៩ត/ហាត ខ្ពស់ជាងទម្លាប់កសិករ១,៤០ត/ហាត និងទទួលបានប្រាក់ចំណេញដុលខ្ពស់រហូតដល់២,៥១លានរៀល/ហាត (ក្រាហ្វិក១២ ស្តាំ) គឺប្រមាណពីរដងនៃទម្លាប់កសិករ។

**ង.៧.៤. ការដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថានកាឌី៖** លទ្ធផលនៃការអង្កេតលើកសិករចំនួន២.៤២២គ្រួសារក្នុងខេត្តចំនួន១២ (តាកែវ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង កំពង់ឆ្នាំង បន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ និងកំពត) បានបង្ហាញថា ក្នុងឆ្នាំ២០១២–១៣កន្លងមក (១)កសិករដាំដុះពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថានកាឌី (ជាពិសេសពូជស្រូវ១០ពូជ) លើស្រែប្រាំង (DS=៩៦៩ហាត) ចំនួន២២% ស្រែដើមរដូវវស្សា (EWS=៤៣៩ហាត) ចំនួន២៥% និងស្រែវស្សា (WS=៣.៣៩០ហាត) ចំនួន៣៧% (២)ដោយឡែកចំពោះពូជស្រូវ ផ្ការំដួល (PRD) ត្រូវបានដាំដុះលើផ្ទៃដីស្រែកណ្តាលរបស់ខេត្តទាំង១២ (១,០៨លានហាត) ចំនួន៤១% និងពូជស្រូវ រាំងជ័យ (RC) ត្រូវបានដាំដុះលើស្រែក្រោម (០,៤៦លានហាត) ចំនួន៥២% (ក្រាហ្វិក១៣ ឆ្វេង)។

ទន្ទឹមនឹងនោះដែរ ចម្លើយពីកសិករចំនួន១.៩៦៦គ្រួសារនៅខេត្តចំនួន៨ (តាកែវ ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងកំពង់ចាម) បានបង្ហាញថា ក្នុងរដូវវស្សាឆ្នាំ២០១៤ ផ្ទៃដីស្រែប្រមាណ៥០% បានដាំពូជស្រូវផ្ការំដួល ១០%ពូជស្រូវរាំងជ័យ ៦%ពូជស្រូវបញ្ចេញដទៃទៀត ២៩%ពូជស្រូវប្រពៃណី និង៥% ពូជស្រូវនាំចូលផ្សេងៗទៀត (ក្រាហ្វិក១៣ ស្តាំ)។ ជាសរុប ក្នុងរដូវវស្សាឆ្នាំ២០១៤ កសិករនៅខេត្តទាំង៨ បានដាំដុះពូជស្រូវដែលបញ្ចេញដោយក្រសួងប្រមាណ៦៦%នៃផ្ទៃដី។

Cambodian Agricultural Research and Development Institute




ក្រាហ្វិក១៣. ភាគរយផ្ទៃដីដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថានកាឌីក្នុងឆ្នាំ២០១៣ (y, ឆ្វេង) និងក្នុងខេត្តចំនួន ៨នារដូវវស្សាឆ្នាំ២០១៤ (ស្តាំ)

លទ្ធផលនៃការធ្វើអង្កេតនៅខេត្តចំនួន៤ (តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង) ក្នុងឆ្នាំ២០១៥ ធៀបជាមួយឆ្នាំ២០១៤បានបង្ហាញជារួមថា ផ្ទៃដីស្រូវវស្សាជាមធ្យមសរុបនៃខេត្តទាំង៤មានប្រមាណ០,៦១៧លានហិកតា ហើយក្នុងនោះ មានស្រូវស្រាល (ស្រែលើ) ២% ស្រូវកណ្តាល (ស្រែកណ្តាល) ៥២% និងស្រូវធ្ងន់ (ស្រែក្រោម) ២៥% (ក្រាហ្វិក១៤)។




ក្រាហ្វិក១៤. ភាគរយផ្ទៃដីដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថានកាឌីនិងពូជកសិករក្នុងខេត្តចំនួន៤ (តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង) លើផ្ទៃដីស្រូវវស្សាសរុប (ស្រូវធ្ងន់=២៥% ស្រូវកណ្តាល=៥២% និងស្រូវស្រាល=២៣%) ក្នុងឆ្នាំ២០១៥ (រង្វង់ខាងក្រៅ) ធៀបនឹងឆ្នាំ២០១៤ (រង្វង់ខាងក្នុង)

ផ្ទៃដីស្រែវស្សាឆ្នាំ២០១៤ប្រមាណ៦១%បានដាំពូជស្រូវដែលបញ្ចេញដោយវិទ្យាស្ថានកាឌី ហើយបរិមាណនេះបានកើនដល់៦៣%ក្នុងឆ្នាំ២០១៥។ ចំពោះស្រូវស្រាល ការដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថានកាឌីក្នុងឆ្នាំទាំង២មានតិចតួចប៉ុណ្ណោះ (១%) នៃផ្ទៃដីស្រែវស្សាទាំងមូល។ ដោយឡែកនៅស្រែកណ្តាល ការដាំដុះពូជស្រូវផ្ការំដួលមានការថយចុះពី៤៨%ក្នុងឆ្នាំ២០១៤ មក៤២%ក្នុងឆ្នាំ២០១៥នៃផ្ទៃដីស្រែវស្សាទាំងមូល។ ការធ្លាក់ចុះនេះ ប្រហែលជាបណ្តាលមកពីការធ្លាក់ចុះនៃតម្លៃស្រូវ (មធ្យមនៃស្រូវសើមនិងស្ងួត) ដែលកសិករលក់ពី១,២៥០ រៀល/គក្រក្នុងឆ្នាំ២០១៣ មក១,១៦៧រៀល/គក្រក្នុងឆ្នាំ២០១៤ ហើយតម្លៃនេះនៅតែបន្តធ្លាក់ចុះមកដល់

Cambodian Agricultural Research and Development Institute

១,០៦០រៀល/គក្រទៀតក្នុងឆ្នាំ២០១៥។ ផ្ទុយទៅវិញ ការដាំដុះពូជស្រូវរាំងជ័យនៅស្រែវស្សាទាំងមូលមានការកើនឡើង១% ទន្ទឹមនឹងការកើនឡើងនូវពូជស្រូវធូន់ជំទៅទៀត (ខា៤ ខា៥ ខា៨ ខា៩ ជាដើម) ពី៣%ក្នុងឆ្នាំ២០១៤ ទៅ៩%ក្នុងឆ្នាំ២០១៥។

**ង.៧.៥. អាហារូបត្ថម្ភរបស់ពូជស្រូវ:** បានយកពូជស្រូវផ្ការំដួល ផ្ការមៀត ផ្ការំដេង សែនពិដោរ ផ្កាច័ន្ទសែនសរ និងដំណើបស្បៃមង្គលទៅវិភាគអាហារូបត្ថម្ភ (Nutrition value) លើអង្ករសម្រិតនិងអង្ករសម្រូបនៅមន្ទីរពិសោធន៍បរទេសស្តង់ដាអន្តរជាតិដោយបានទទួលលទ្ធផលដូចមានក្នុងតារាង៦។ លក្ខណៈដែលគួរឲ្យចាប់អារម្មណ៍បំផុតនោះ គឺពូជស្រូវផ្ការមៀតមានជាតិដែក (Fe) ខ្ពស់និងមានវីតាមីនអា (Vitamin A) ទាំងក្នុងអង្ករសម្រិតនិងអង្ករសម្រូប ដែលជាទូទៅពូជស្រូវភាគច្រើនមិនមានសារធាតុទាំងនេះខ្ពស់ (ដែក) ឬគ្មានតែម្តង (វីតាមីនអា)។ លទ្ធផលនេះត្រូវបានបង្ហោះនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានកាឌី (www.cardi.org.kh) សម្រាប់អ្នកពាក់ព័ន្ធយកទៅប្រើប្រាស់។

តារាង៦. អាហារូបត្ថម្ភមានក្នុងអង្ករសម្រិត (WR) និងអង្ករសម្រូប (BR) របស់ពូជស្រូវផ្ការំដួល (PRD) ផ្ការមៀត (PRM) ផ្ការំដេង (PRDg) សែនពិដោរ (SPD) ផ្កាច័ន្ទសែនសរ (PCSS) និងដំណើបស្បៃមង្គល (DNSMK)

| No | Parameter | Unit | PRD | | PRM | | PRDg | | SPD | | PCSS | | DNSMK |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | WR | BR | WR | BR | WR | BR | WR | BR | WR | BR | WR |
| 1 | Fe | mg/kg | 2.35 | 11.2 | 12.9 | 17.7 | 5.89 | 17.0 | | 15.9 | 9.22 | 12.3 | 2.53 |
| 2 | Carbohydrate | g/100g | 79.1 | 75.9 | 79.5 | 75.6 | 78.8 | 75.4 | 80.9 | 76.9 | 79.9 | 78.1 | 79.7 |
| 3 | Dietary fiber | g/100g | 1.99 | 3.82 | 2.17 | 11.1 | 0.71 | 2.63 | 2.38 | 3.85 | 1.10 | 4.38 | 0.47 |
| 4 | Energy | kcal/100g | 356 | 366 | 359 | 364 | 351 | 362 | 365 | 377 | 361 | 380 | 356 |
| 5 | Protein | g/100g | 7.32 | 8.22 | 8.34 | 8.77 | 7.11 | 7.84 | 7.22 | 7.88 | 7.77 | 8.24 | 7.53 |
| 6 | Total fat | g/100g | 1.16 | 3.29 | 0.80 | 2.94 | 0.81 | 3.17 | 1.40 | 4.20 | 1.15 | 3.82 | 0.79 |
| 7 | Cholesterol | mg/100g | ND | ND | ND | ND | ND | ND | ND | ND | ND | ND | ND |
| 8 | Polyunsat.fat | g/100g | 0.40 | 1.03 | 0.20 | 1.00 | 0.29 | 1.02 | 0.50 | 1.34 | 0.47 | 1.05 | 0.33 |
| 9 | Thiamine | mg/kg | 0.81 | 2.39 | 1.10 | 4.70 | ND | 3.16 | 0.72 | 2.50 | 0.60 | 3.20 | 0.8 |
| 10 | Vitamin A | mg/kg | ND | ND | 0.83 | 0.81 | ND | ND | ND | ND | ND | ND | ND |
| 11 | Vitamin B2 | mg/kg | 0.70 | 2.67 | ND | ND | ND | ND | | 2.73 | ND | ND | ND |
| 12 | Vitamin B3 | mg/kg | 1.60 | 10.2 | ND | ND | 1.1 | 4.47 | | 10.8 | 2.8 | 1.6 | 1.80 |
| 13 | Vitamin B6 | mg/kg | ND | ND | ND | ND | ND | ND | | ND | ND | ND | ND |
| 14 | Vitamin C | mg/kg | ND | ND | ND | ND | ND | ND | | ND | ND | ND | ND |
| 15 | Vitamin D | mcg/kg | ND | 36.0 | ND | ND | ND | ND | | 28.0 | ND | ND | ND |
| 16 | Vitamin E | mg/kg | ND | 5.0 | ND | 5.1 | ND | ND | | 8.0 | ND | ND | ND |
| 17 | Vitamin K1 | mg/kg | ND | ND | ND | ND | ND | ND | | ND | ND | ND | ND |
| 18 | Vitamin B12 | mcg/kg | ND | ND | ND | ND | ND | ND | | ND | ND | ND | ND |

ND = មិនអាចកំណត់បាន

**ង.៧.៦. ការផ្សព្វផ្សាយបច្ចេកទេស៖** បានធ្វើទិវាស្រែបង្ហាញ វាយតម្លៃ និងបណ្តុះបណ្តាលកសិករសរុបចំនួន១៤០លើក ដែលមានកសិករចូលរួមសរុបចំនួន៦.០១២នាក់ ព្រមទាំងបានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន១.៣០៤គ្រួសារ ដោយក្នុងមួយគ្រួសារបានចំនួន៥គីឡូក្រាម មានសរុបចំនួន៦.៥២០គក្រ ហើយដែលកសិករទាំងនោះផលិតជាគ្រាប់ពូជបានប្រមាណ១៨៣តោន (គិតមកត្រឹមដំណាច់ឆ្នាំ២០១៦) ទុកសម្រាប់ប្រើប្រាស់ក្នុងឆ្នាំបន្ទាប់។ ទន្ទឹមនឹងនេះ បានចែកគ្រាប់ពូជគ្រឹះនៃពូជស្រូវស្មាច់០២ ដែលទើបបញ្ចេញជូនកសិករសហគមន៍កសិកម្មស្រូវស្មាច់កំពង់រោទិ៍ចំនួនប្រមាណ២០០គក្រ សម្រាប់ដាំដុះក្នុងឆ្នាំ២០១៧ និងបានចែកគ្រាប់ពូជស្រូវដំណើបស្បៃមង្គលជូនសហគមន៍ក្រឡានថ្មគ្រែខេត្តក្រចេះដាំដុះក្នុងឆ្នាំ២០១៧ សម្រាប់ដុតក្រឡានផងដែរ។

Cambodian Agricultural Research and Development Institute

**ង.៧.៧. ការពង្រឹងនិងអភិវឌ្ឍធនធានមនុស្ស៖** មន្ត្រីវិទ្យាស្ថានកាឌីចំនួន៤រូប បានចូលរួមបង្រៀនថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ បានដឹកនាំនិស្សិតស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន៧៧នាក់។ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន២៩វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៩៣២នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្រៅប្រទេសចំនួន១១៥លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានកាឌីចូលរួមចំនួន២២០នាក់។ មន្ត្រីសរុបចំនួន៥រូប កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (៣រូប) និងថ្នាក់បណ្ឌិត (២រូប) នៅក្រៅប្រទេស។

**ង.៧.៨. ការបោះពុម្ពនិងផ្សព្វផ្សាយ៖** បានបោះពុម្ពរបាយការណ៍សង្ខេបប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំ ព្រឹត្តិប័ត្រព័ត៌មានកសិករ និងបោះពុម្ពឡើងវិញនូវសៀវភៅបច្ចេកទេសកសិកម្ម ព្រឹត្តិប័ត្រព័ត៌មានកសិករ និងឯកសារផ្សេងៗ បានសរុបចំនួន៩៦.០៩២ច្បាប់ ហើយបានបែងចែកចំនួនសរុប៩២.៣៨៧ច្បាប់ (៩៦%)។

**ង.៧.៩. គេហទំព័រវិទ្យាស្ថាន** (Website)៖ ចំនួនអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានកាឌីមានការកើនឡើងគួរឲ្យចាប់អារម្មណ៍ គឺកើនពីចំនួន៨៩៦នាក់/ថ្ងៃក្នុងឆ្នាំ២០១៣ ទៅ១.១៨៩នាក់/ថ្ងៃក្នុងឆ្នាំ២០១៤ រហូតដល់២.០៧៩នាក់/ថ្ងៃក្នុងឆ្នាំ២០១៦។

**ង.៧.១០. អត្ថបទវិទ្យាសាស្ត្រ៖** បានសរសេរនិងចូលរួមសរសេរ ព្រមទាំងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ និងសៀវភៅសន្និសីទនានាបានចំនួន៣១អត្ថបទដែលផ្តោតលើប្រធានបទជាភាសាអង់គ្លេសដូចខាងក្រោម៖


1. Kamoshita A., Ikeda H., Yamagishi J., **Lor B.** and **Ouk M.** (2016). Residual effects of cultivation methods on weed seed banks and weeds in Cambodia. Weed Biology and Management 16, 93-107.
2. P.L. Poulton, N.P. Dalgliesh, **S. Vang**, C.H. Roth (2016). Resilience of Cambodian lowland rice farming systems to future climate uncertainty. In: Field Crops Research 198 (2016) 160-170.
3. Jonh AhnChun, Sanai Li, Qingguo Wang, Woo-Seop Lee, Eun-Jeong Lee, Nina Horstmann, Hojeong Park, **Touch Veasna, Lim Vandy, Khok Pros, Seng Vang** (2016). Assessing rice productivity and adaptation strategies for Southeast Asia under climate change through multi-scale crop modeling. In: Africultural Systems 143 (2016) 14-21.
4. **Kong Kynet, Orn Chhourn, Uong Peou, Ouk Sothea, Tho Thanak, Sieng Layheng, Nou Kihen, Thun Vathany, Sakhan Sophany and Ouk Makara** (2016). Two promising climate resislience rice-breeding lines in rainfed lowland of Cambodia. In: The 3rd National Conference on Agriculture and rural Development “Enhancing the Rural Economy through Sustainable Development in Agriculture”, 26-27 November 2016 Svay Rieng University, pp. 3-4.
5. **Orn Chhourn, Nou Kihen, Kong Kynet, Mak Leakhena, Thun Vathany, Sakhan Sophany and Ouk Makara** (2016). Promising heat tolerant breeding lines of rice for Cambodian farmers. In: The 3rd National Conference on Agriculture and rural Development “Enhancing the Rural Economy through Sustainable Development in Agriculture”, 26-27 November 2016 Svay Rieng University, pp. 5-6.
6. So Makable, **Kynet Kong**, Hiroyuki Niimi, Ikuo Nakamura (2016). Growth profiles of transgenic tobacco plants expressing rice *45S rRNA* gene. Global Advanced Research Journal of Agricultural Science, (accepted).
7. Gopal Selvakumar, Kiyoon Kim, Dever Walitang, **Mak Chanratana**, Yeongyeong Kang, Bongnam Chung and Tongmin Sa (2016). Trap Culture Technique for Propagation of *Arbuscular Mycorrhizal* Fungi using Different Host Plants. *Korean Journal of Soil Science and Fertilizer* **49**: 608-613.


Cambodian Agricultural Research and Development Institute

8. Wansik Shin, Ashaduzzaman Siddikee, Manoharan Melvin Joe, Abitha Benson, Kiyoon Kim, Gopal Selvakumar, Yeongyeong Kang, Seonyoung Jeon, Sandipan Samaddar, Poulami Chatterjee, Dever Walitang, **Mak Chanratana**, and Tongmin Sa (2016). Halotolerant Plant Growth Promoting Bacteria Mediated Salinity Stress Amelioration in Plants. *Korean Journal of Soil Science and Fertilizer* **8**: 355-367

9. ConcepcionJ.C.T., **Ouk M.**, Zhao D. and Fitzgerald M.A. (2015). The need for new tools and investment to improve the accuracy of selecting for grain quality in rice. Field Crops Research 182, 60-67.

10. Birch, C.J., Bonney, L.B., Ives, S. W., McPhee, J. Bounneuang, D., **Seng Vang**, **Sokun Bo** and Sacklokham, S. (2015). Whole of System and Value Chain Analyses reveal research needs in horticulture in Laos and Cambodia. pp72-73 in Book of Abstracts, 'Meeting the Challenge of Productivity in the Tropics, Tropical Agriculture Conference, Brisbane, 16-18 November 2015, Brisbane, Australia.

11. **Chanthy, P.**, R. J. Martin, R. V. Gunning and N. R. Andrew (2015). "Influence of Temperature and Humidity regimes on the Developmental Stages of Green Vegetable Bug, Nezara Viridula (L.) (Hemiptera: Pentatomidae) from Inland and Coastal Populations in Australia." Gen. Appl. Ent 43: 37-55.

12. **Chhourn Orn**, Rieko Shishido, Masahiro Akimoto, Ryo Ishikawa, Than Myint Htun, Ken-Ichi Nonomura, Yohei Koide, Men Sarom, **Seng Vang, Sakhan Sophany, Ouk Makara**, and Takashige Ishii (2015). Evaluation of genetic variation among wild rice populations in Cambodia. Breeding Science 65: 430–437.

13. Ntui, V. O., **K. Kong**, R. S. Khan, T. Igawa, G. J. Janavi, R. Rabindran, I. Nakamura and M. Mii (2015). "Resistance to Sri Lankan Cassava Mosaic Virus (SLCMV) in Genetically Engineered Cassava cv. KU50 through RNA Silencing." PLoS ONE 10(4): 1-23.

14. Perry L Poulton, Neal P Dalgliesh, **Seng Vang, Touch Veasna**, Philip Charlesworth, Alison Laing (2015). Resilience of smallholder farmers in Cambodian lowland rice ecosystems in managing for future climate uncertainty. In: "Building Productive, Diverse and Sustainable Landscapes" - Proceedings of the 17th ASA Conference, 20–24 September 2015, Hobart, Australia. Website: www.agronomy2015.com.au

15. Perry L Poulton, **Touch Veasna**, Neal P Dalgliesh, **Vang Seng** (2015). Applying simulation to improve rice varieties in reducing the on-farm yield gap in Cambodian lowland rice ecosystems. Expl Agric. (2015), volume 51 (2), pp. 264–284.

16. **Seng Vang and Hin Sarith** (2015). Land resources of Cambodia: A review of knowledge and management. In: "ISC 2015 - Sustainable Uses of Soil in Harmony with Food Security" – Proceedings of the International Soil Conference, 18-21 August 2015, Cha Am, Thailand.

17. **Seng Vang, Hin Sarith, Touch Veasna, Lim Vanndy, and Ly Tyneth** (2015). Effects on soil qualities and crop yields of applied rice husk biochar fortified with inorganic NPK or organic fertilizers in rice-growing soils of Cambodia. In: "Proceedings of the 2nd National Conference on Agriculture and Rural Development", 21 November 2015, Royal University of Agriculture, Phnom Penh, Cambodia, pp. 1- 4.

18. Vote C., Oeurng C., Sok T., Phongpacith C., Inthavong T., **Seng V.**, Eberbach P. and Hornbuckle J. (2015). A comparison of three empirical models for assessing cropping options in a data-sparse environment, with reference to Laos and Cambodia. ACIAR Technical Reports No. 87. Australian Centre for International Agricultural Research: Canberra. 30 pp.

19. Fukuta, Y., I. Koga, T. Ung**, K. Sathya**, M. Obara, **H. Yadana** and N. Hayashi (2014). "Pathogenicity of Rice Blast (*Pyricularia oryzae* Cavara) Isolates from Cambodia." JARQ48(2): 155-166.

20. Khan, R. S., N. A. Darwish, B. Khattak, V. O. Ntui, **K. Kong**, K. Shimomae, I. Nakamura and M. Mii (2014). "Retransformation of Marker-Free Potato for Enhanced Resistance Against Fungal Pathogens by Pyramiding Chitinase and Wasabi Defensin Genes." Mol Biotechnol 1-10.

21. Pathogenicity of Rice Blast (Pyricularia oryzae Cavara) Isolates from Cambodia. JARQ 48 (2), 155 - 166 (2014) http://www.jircas.affrc.go.jp. Yoshimichi Fukuta, Ikumi Koga, **Toch Ung**, **Khay Sathya**,

Cambodian Agricultural Research and Development Institute

Akiko Kawasaki-Tanaka, Yohei Koide, Nobuya Kobayashi, Mitsuhiro Obara, **Hun Yadana** and Nagao Hayashi.

22. P. L. Poulton, T. Veasna, N. P. Dalgliesh and **V. Seng** (2014). Applying simulation to improve rice varieties in reducing the on-farm yield gap in Cambodian lowland rice ecosystems. Expl Agric.: page 1 of 21. Cambridge University Press 2014.

23. **Kong, K.**, V. O. Ntui, S. Makabe, R. S. Khan, M. Mii and I. Nakamura (2014). "Transgenic tobacco and tomato plants expressing Wasabi defensin genes driven by root-specific LjNRT2 and AtNRT2.1 promoters confer resistance against Fusarium oxysporum." Plant Biotechnology 31, : 89–96.

24. Ntui, V. O., **K. Kong**, P. Azadi, R. S. Khan, D. P. Chin, T. Igawa, M. Mii and I. Nakamura (2014). "RNAi-Mediated Resistance to Cucumber Mosaic Virus (CMV) in Genetically Engineered Tomato." American Journal of Plant Sciences, 2014, 5: 554-572.

25. Poulton, P. L., **T. Veasna**, N. P. Dalgliesh and **V. Seng** (2014). “Appying Simulation to Improve Rice varieties in Reducing the On-farm Yield Gap in Cambodia Lowland Rice ecosystems.” Expl Agric. @ Cambridge University Press: 1-21.

26. Andrew Nelson, Tri Setiyono, Arnel B. Rala, Emma D. Quicho, Jeny V. Raviz, Prosperidad J. Abonete, Aileen A. Maunahan, Cornelia A. Garcia, Hannah Zarah M. Bhatti, Lorena S. Villano, Pongmanee Thongbai, Francesco Holecz, Massimo Barbieri, Francesco Collivignarelli, Luca Gatti, Eduardo Jimmy P. Quilang, Mary Rose O. Mabalay, Pristine E. Mabalot, Mabel I. Barroga, Alfie P. Bacong, Norlyn T. Detoito, Glorie Belle Berja, Frenciso Varquez, Wahyunto, Dwi Kuntjoro, Sri Retno Murdiyati, Sellaperumal Pazhanivelan, Pandian Kannan, Petchimuthu Christy Nirmala Mary, Elangovan Subramanian, Preesan Rakwatin, Amornrat Intrman, Thana Setapayak, Sommai Lertna, Vo Quang Minh, Vo Quoc Tuan, Trinh Hoang Duong, Nguyen Huu Quyen, Duong Van Kham, **Sarith Hin, Touch Veasna**, Manoj Yadav, Chharom Chin and Nguyen Hong Ninh (2014). Towards an Operational SAR-Based Rice Monitoring System in Asia: Examples from 13 Demonstration Sites across Asia in the RIICE Project Special Issue of Remote Sensing in Food Production and Food Security, Remote Sensing, ISSN 2072-4292. http://www.mdpi.com/2072-4292/6/11/10773/s1/.

27. Christian H. Roth, Zainul Abedin, Ravindra Adusumilli, Peter R. Brown, Philip Charlesworth, Neal Dalgliesh, Don S. Gaydon, Clemens Grünbühel, Zvi Hochman, Thavone Inthavong, Phil Kokic, Iqbal Khan, Alison Laing, Soeun Mak, Minea Mao, Uday Nidumolu, Vanthong Phengvichith, Perry Poulton, Md. Harunur Rashid, D. Raji Reddy, V. Ratna Reddy, Tom Say, **Seng Vang**, Silinthone Sacklokham, Gade Sreenivas, Chiranjeevi Tallapragada, Touch Veasna, Monica van Wensveen and Liana J. Williams (2014). “Insights for policy from the ‘Adaptation to Climate Change in Asia’ project” in A policy dialogue on rice futures: rice-based farming systems research in the Mekong region. ACIAR Procedding No. 142. P. 120-124. http://aciar.gov.au/files/pr142-web.pdf/.

28. Geoff Beecher, David Johnson, Jack Desbiolles, Sam North, Rajinder Singh, Som Bunna, Ngin Chhay, Joel Janiya, Tina Dunn, **Seng Vang**, Chuong Sophal, **Men Panchak Roat**, Chea Sovandina, **Touch Veasna**, Gavin Tinning and Bob Martin (2014). “Improved rice establishment and productivity in Cambodia and Australia” in A policy dialogue on rice futures: rice-based farming systems research in the Mekong region. ACIAR Proceeding No. 142. P. 43-46. http://aciar.gov.au/files/pr142-web.pdf/.

29. Hin, S., Bell, R.W., Newsome, D. and **Seng, V.** (2014). Mung Bean Response to Lime Application on Acid Sands of South-Eastern Cambodia: Glasshouse Study. In Proceedings of The National Scientific Conference on Agriculture and Rural Development, 31 October 2014, RUA, Phnom Penh, Cambodia.

30. **Touch Veasna, Som Bunna, Men Pagnchak Roat, Lim Vanndy, Pao Sinath, Seng Vang,** Oeurng Chantha, Noum Viraday, Men Nareth, Prum Kanthel, H.E. Pich Veasna, Theng Tara, Uch Hing, Marisa Collins, John Hornbuckle, Wendy Quayle, David Smith and Roy Zandona (2014). “Improved irrigation water management to increase rice productivity in Cambodia” in A policy dialogue on rice futures: rice-based farming systems research in the Mekong region. ACIAR Procedding No. 142. P. 92-102. http://aciar.gov.au/files/pr142-web.pdf/

Cambodian Agricultural Research and Development Institute

31.Kamoshita, A., **Ouk, M.** (2014). Field level damage of deepwater rice by the 2011 Southeast Asian Flood in a flood plain of Tonle Sap Lake, Northwest Cambodia. Paddy & Water Environment 13, 455-463.

## ង.៨. មន្ទីរពិសោធន៍

**ង.៨.១. មន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា៖** បាននិងកំពុងអនុវត្ត Extract DNA របស់ស្រទ្បាយកូនបង្កាត់ចំនួន១០ប្រជាករ ដែលមានស្រទ្បាយសរុបចំនួន៥៧៥ស្រទ្បាយដើម្បីវិភាគរកវត្តមានពន្ធុក្រអូបនៅក្នុងស្រទ្បាយនីមួយៗ។ ស្រទ្បាយចំនួន៤៣ក្នុងចំណោម៧០ស្រទ្បាយ ដែលបានវិភាគរួចត្រូវបានរកឃើញមានវត្តមានពន្ធុក្រអូប (អូមូសីកូត) ដែលនេះជាលទ្ធផលដ៏សុក្រិតមួយសម្រាប់បន្តការងារស្រាវជ្រាវនៅជំហានបន្ទាប់ទៀត។

**ង.៨.២. មន្ទីរពិសោធន៍គុណភាពអង្ករ៖** បានអនុវត្តលើការវិភាគគុណភាពអង្ករលើលក្ខណៈរូបសាស្ត្រប្រើម៉ាស៊ីន S21 ជាតុអាមីឡូស សីតុណ្ហភាពចម្អិននិង Gel consistency សរុបបានចំនួន២៨៦សំណាក។

**ង.៨.៣. មន្ទីរពិសោធន៍ជាលិកាវប្បកម្មដំណាំ៖** បានបន្តការដាំពង្រីកនិងអភិរក្សពូជដំណាំតាមការធ្វើជាលិកាវប្បកម្មទៅលើដំណាំចំនួន៧ប្រភេទ ដែលក្នុងនោះមានដំណាំចេកចំនួន៥០សំណាក ដំឡូងឈើចំនួន៤ពូជ ដំឡូងជ្វាចំនួន៣ស្រទ្បាយ ដំឡូងបារាំងចំនួន៤ស្រទ្បាយ អំពៅ៥សំណាក ដើមដំបងយក្សចំនួន១សំណាកនិងផ្កាចំនួន៦ពូជ សរុបចំនួន៧៣ពូជ/ស្រទ្បាយដំណាំ។

**ង.៨.៤. មន្ទីរពិសោធន៍វិភាគដីនិងទឹក៖** បានវិភាគសំណាកដីចំនួន១.៨៥០សំណាក លើ pH, EC, $NH_4^+$, $Nw^-$, soil water content, OC, OM, N និង P ព្រមទាំងបានវិភាគសំណាកទឹកចំនួន៣៣៦សំណាកលើ pH, EC, Fe, Al, $NH_4^+$, $NO_3^-$, ភាពកករ (Turbidity) និងអាល់កាឡាំង (Alkalinity)។

**ង.៨.៥. មន្ទីរពិសោធន៍រុក្ខរោគសាស្ត្រ៖** បានធ្វើការបណ្តុះរកភ្នាក់ងារបង្ករោគដែលប្រមូលបាននៅក្នុងវិទ្យាស្ថានកាឌី ខេត្តព្រៃវែង កំពង់ធំ បាត់ដំបងនិងតាកែវលើដំណាំស្រូវចំនួន០៨ប្រភេទរួមមានជំងឺអុជខ្មោត ឆ្នូតស្លឹកពណ៌លឿងបង្ករដោយបាក់តេរី ច្រេះស្លឹក រលាកស្រទបស្លឹក ឆ្នូតបាក់តេរីលើស្លឹកខ្វាររំអំបោះខ្មោត អុជខ្មោតវែងនិងផ្សិតបែតងនិងលើដំណាំពោតចំនួន២ប្រភេទ (ជំងឺអុជខ្មោតនិងរលាកស្រទបស្លឹក)។

**ង.៨.៦. មន្ទីរពិសោធន៍កីណជាតិសាស្ត្រ៖** បានប្រមូលសត្វល្អិតលើដំណាំស្រូវចំនួន១៧ប្រភេទរួមមាន កក់ជ្រុង កក់ ភ្នែកក្តាម កក់ឆ័ត្រតូច ស្មៅពុកមាត់បង្កង ស្មៅបែកក្បាលគ្មានកន្ទុយ ស្មៅតាសៀវ ត្រកួន កំពីងពួយ កណ្តៀងឈើ ជន្លង់ភ្នំ ស្មៅគោក ស្មៅទឹក ស្មៅជើងតុកកែ ស្មៅបែកក្បាល ស្មៅកន្ទុយក្ងោក ស្មៅចិញ្ចៀន និងច្រាច់។

# ច. សន្និដ្ឋាន

ក្រុមប្រឹក្សាភិបាលអាណត្តិទី៥បានវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវនិងសាមគ្គីភាពរបស់ថ្នាក់ដឹកនាំនិងមន្ត្រីនិយោជិតទាំងអស់របស់វិទ្យាស្ថានកាឌីក្នុងការងារប្រតិបត្ត បង្កើតបាននូវបច្ចេកវិទ្យានិងលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មជាមូលដ្ឋានជាច្រើនសម្រាប់គ្រប់អ្នកពាក់ព័ន្ធ រួមទាំងអ្នកធ្វើគោលនយោបាយនិងកសិករប្រើប្រាស់ក្នុងការជំរុញផលិតភាព ពិពិធកម្ម និងពាណិជ្ជូបណីយកម្មកសិកម្ម ជាមួយនឹងការ

Cambodian Agricultural Research and Development Institute

ចូលរួមចែករំលែកបទពិសោធន៍ល្អៗដល់និស្សិតនិងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ក្នុងការឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៤-២០១៨របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ វិទ្យាស្ថានកាឌីក៏បានបង្ហាញពីភាពរីកចម្រើនយ៉ាងច្រើនទៅលើការស្តារហេដ្ឋារចនាសម្ព័ន្ធការងារស្រាវជ្រាវ ការធ្វើទំនាក់ទំនងជាមួយភ្ញៀវជាតិនិងអន្តរជាតិ ដែលធ្វើឲ្យវិទ្យាស្ថានកាន់តែមានភាពល្បីល្បាញពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់លោកនាយកវិទ្យាស្ថានត្រូវបានក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រឆ្នើម** ប្រចាំឆ្នាំសិក្សា២០១៦-២០១៧ និងជាពិសេសវិទ្យាស្ថានកាឌីទទួលបានការកោតសសើរពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានវាយតម្លៃខ្ពស់ដល់វិទ្យាស្ថានកាឌី ដែលបានបញ្ចេញពូជស្រូវថ្មីធន់នឹងការប្រែប្រួលអាកាសធាតុចំនួន៥ពូជ និងពូជពោតដំណើប១ពូជក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ និងជាពិសេសពានរង្វាន់អង្ករពូជស្រូវផ្ការំដួលល្អប្រណិតនិងមានរសជាតិជាងគេក្នុងពិភពលោករយៈពេល៣ឆ្នាំ (២០១២-២០១៤) ជាប់ៗគ្នាកន្លងមកនេះ។

ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាភិបាលក៏សង្កេតឃើញថា វិទ្យាស្ថានកាឌីជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជាការចំណាយពេលវេលាកែសម្រួលទៅតាមនីតិវិធីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មី ការប៉ុនប៉ងដោះដូរទីតាំង ការបាត់បង់មន្ត្រីជំនាញផ្នែកស្រាវជ្រាវ គ្រប់គ្រង និងហិរញ្ញវត្ថុទន្ទឹមនឹងមន្ត្រីរាជការនៅមានចំនួនតិច ប្រព័ន្ធទឹកស្អាតមិនទាន់មកដល់មធ្យោបាយដឹកជញ្ជូននិងគ្រឿងយន្តកសិកម្មមានសភាពចាស់ទ្រុឌទ្រោមជាដើម។

## ឆ. សំណូមពរ

ក្នុងបរិបទនៃការឈានឡើងពីផលិតកម្មបំពេញតម្រូវការហូបចុកទៅផលិតកម្មកសិកម្មតាមតម្រូវការទីផ្សារប្រកបដោយគុណភាព សុវត្ថិភាព និងភាពប្រកួតប្រជែង និងជាពិសេសដើម្បីសម្រេចបានទៅនឹងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបិទសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧កន្លងមកនេះ ដែលបានបញ្ជាក់ថា វិទ្យាស្ថានកាឌីនឹងត្រូវដើរតួនាទីកាន់តែសកម្មនៅក្នុងបរិការដែលពិភពលោកស្ថិតក្នុងពេលវេលាដ៏លំបាកទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងបានលើកទឹកចិត្តឲ្យមន្ត្រីរាជការនិងអ្នកបច្ចេកទេសនៅវិទ្យាស្ថានកាឌីបន្តស្វែងរកពូជស្រូវថ្មីៗ និងពូជដំណាំផ្សេងទៀតរួមទាំងផ្កា ក្រុមប្រឹក្សាភិបាលយល់ឃើញថា ត្រូវតែលើកកម្ពស់សមត្ថភាពអនុវត្តការងារស្រាវជ្រាវរបស់វិទ្យាស្ថានកាឌីជាបន្ទាន់និងចាំបាច់។ ដើម្បីលើកកម្ពស់សមត្ថភាពនេះ ក្រុមប្រឹក្សាភិបាលបានយល់ស្របតាមសំណូមពរសំខាន់ៗរបស់វិទ្យាស្ថានកាឌីមួយចំនួនដូចខាងក្រោម៖

- វិនិយោគលើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ (ប្រព័ន្ធស្រោចស្រពនិងបញ្ចេញទឹក ភ្ជាប់បណ្តាញទឹកស្អាត) បំពាក់ឬបំពេញបង្គ្រប់ឧបករណ៍និងសម្ភារៈរូបវន្តរបស់មន្ទីរពិសោធន៍និងធនាគារពន្ធុដំណាំកសិកម្ម ផ្តល់នូវមធ្យោបាយដឹកជញ្ជូននិងគ្រឿងយន្តកសិកម្មថ្មីៗ និងរៀបចំនូវប្រព័ន្ធសំណាញ់ការពារចាបនិងកណ្តុរសម្រាប់ស្រែពិសោធន៍ក្នុងវិទ្យាស្ថានកាឌីជាដើម។
- វិនិយោគលើភាពទន់ក្នុងការផ្តល់បន្ថែមនូវមន្ត្រីរាជការជំនាញគ្រប់ផ្នែក គោលនយោបាយលើកទឹកចិត្តដល់មន្ត្រីស្រាវជ្រាវនិងគ្រប់ផ្នែកទាំងអស់របស់វិទ្យាស្ថានកាឌី

Cambodian Agricultural Research and Development Institute

- ដំឡើងវិទ្យាស្ថានពីថ្នាក់នាយកដ្ឋានទៅអគ្គនាយកដ្ឋាន ដើម្បីបង្កើននូវប្រសិទ្ធភាពនិងពង្រីកវិសាលភាពការងារស្រាវជ្រាវដំណាំកសិកម្មឲ្យកាន់តែទូលំទូលាយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងការប្រែប្រួលក្នុងបរិបទនៃសាកលភាវូបនីយកម្ម។
- គាំទ្រមិនឲ្យមានការដោះដូរទីតាំងវិទ្យាស្ថានកាឌីបច្ចុប្បន្ន ដើម្បីថែរក្សាអត្តសញ្ញាណនិងភាពងាយស្រួលធ្វើដំណើរ និងលើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្មថ្នាក់ជាតិនិងតំបន់។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧

**នាយកវិទ្យាស្ថាន**

**អ៊ុក ម៉ាការា**

Cambodian Agricultural Research and Development Institute




**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពិនិត្យស្រូវ-អង្កររបស់ពូជស្រូវល្អៗដែលបានបញ្ចេញដោយវិទ្យាស្ថានកាឌី ក្នុងទិវាស្រូវ-អង្ករលើកទី៥



ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីពិនិត្យស្រូវ-អង្ករនិងភ្លក់រសជាតិបាយក្នុងពិធីបើកវេទិកាស្រូវ-អង្ករលើកទី៤

Cambodian Agricultural Research and Development Institute



លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ពិនិត្យសណ្តែក ពោត និងអង្ករក្នុងពិធីទិវាស្បៀងអាហារពិភពលោក




ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី ពិនិត្យស្រូវ-អង្ករ ដែលបានបញ្ចេញដោយវិទ្យាស្ថានកាឌីក្នុងពិធីរំឭកខួប៣០ឆ្នាំនៃភាពជាដៃគូសហប្រតិបត្តិការរវាងកម្ពុជា និង IRRI នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

Cambodia Development Resource Institute



ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បំពាក់មេដាយ ជូនដល់ **លោកនាយកវិទ្យាស្ថាន** ជា "**អ្នកវិទ្យាសាស្ត្រឆ្នើម**" សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧




អ្នកស្រាវជ្រាវដំណាំស្រូវរបស់កម្ពុជាទទួលបានការកោតសរសើរអំពីស្នាដៃការងារពី IRRI

Cambodian Agricultural Research and Development Institute










លោកនាយកវិទ្យាស្ថានត្រូវបានជ្រើសរើសជា **អ្នកវិទ្យាសាស្ត្រស្រូវឆ្នើម**
និងជា **ឯកអគ្គរាជទូតវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** តំណាងប្រទេសកម្ពុជា ប្រចាំអាស៊ាន

Cambodian Agricultural Research and Development Institute



កិច្ចប្រជុំពិនិត្យនិងពិភាក្សាឆ្លងសេចក្តីព្រាងអនុក្រឹត្យនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
ក្រោមកិច្ចដឹកនាំរបស់ **ឯកឧត្តម ខ្ញឹម គឹមស៊ា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ទិវាស្រែបង្ហាញពីការវាយតម្លៃពូជស្រូវផ្ការំដួលប្រាំង ដឹកនាំដោយ **ឯកឧត្តម ម៉ម អំណាត់** រដ្ឋលេខាធិការ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Cambodian Agricultural Research and Development Institute



ការទទួលជួបគណៈប្រតិភូអន្តរក្រសួង នៃប្រទេសបង់ក្លាដេស



ទស្សនកិច្ចរបស់បណ្ឌិត Matthew K. Morell អគ្គនាយកវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI)

Cambodian Agricultural Research and Development Institute



ទស្សនកិច្ចរបស់បណ្ឌិត G.S. Khush សាស្ត្រាចារ្យសកលវិទ្យាល័យ California
និងជាអតីតនាយកផ្នែករុក្ខជម្រើសវិទ្យារបស់វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI)




កិច្ចប្រជុំលើកទី១២ នៃក្រុមការងារបច្ចេកទេសអាស៊ានស្តីពីការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម (ATWGARD)
ក្រោមអធិបតីភាព **ឯកឧត្តម សាន វណ្ណាទី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Cambodian Agricultural Research and Development Institute




ពិធីសំណេះសំណាលនិងចែកគ្រាប់ពូជស្រូវដល់កសិករនៅខេត្តពោធិ៍សាត់និងកំពង់ឆ្នាំង

Cambodian Agricultural Research and Development Institute



វគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជស្រូវនិងបច្ចេកទេសក្រោយពេលប្រមូលផលនៅខេត្តព្រៃវែងនិងស្វាយរៀង



កសិករចូលរួមវាយតម្លៃលើស្រទ្បាយស្រូវផ្ការំដួលប្រាំងនៅខេត្តតាកែវ

Cambodian Agricultural Research and Development Institute



សហគមក្រទ្បានថ្មគ្រែ ខេត្តក្រចេះទទួលស្គាល់ថា ក្រទ្បានអង្ករដំណើបស្បៃមង្គលមានរសជាតិឆ្ងាញ់និងល្អជាង ពូជស្រូវដំណើបរបស់គាត់ និងការប្រគល់គ្រាប់ពូជស្រូវដំណើបស្បៃមង្គលដល់សហគមន៍ចំនួន១០០គីឡូក្រាម។



ការសាបពូជស្រូវដែលទើបប្រមូលបានសម្រាប់ស្ទង់វាយតម្លៃលក្ខណៈ និងស្រែយុវកម្មពូជស្រូវដែលបានអភិរក្ស

Cambodian Agricultural Research and Development Institute



សកម្មភាពផ្សេងៗនៃការងារស្រាវជ្រាវ

Cambodian Agricultural Research and Development Institute




សកម្មភាពផ្សេងៗនៃការងារស្រាវជ្រាវ

Cambodian Agricultural ... Institute

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១.៥៣៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា អាណត្តិទី៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ច ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Cambodian Agricultural Research and Development Institute

# សម្រេច

**មាត្រា១..**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលប្រចាំវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សម្រាប់អាណត្តិទី៥ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- លោក **ហ៊ួត ប៊ុនណារី** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្តម **ទ្រី មេង** | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣- លោក **សឿង សាំងអេម** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- លោក **ខេង្យ រ៉ូដាឌុល** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក **ជា ស៊ីណា** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៦- លោក **អេង គីមលី** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- លោក **ឃូ សុត្ថា** | តំណាងក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៨- លោក **ស្រ៊ុន សុខុម** | តំណាងអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៩- លោក **អ៊ុក ម៉ាករា** | នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១០- លោកស្រី **សេង មុំ** | ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ផ្នែកកសិកម្ម | សមាជិក |
| ១១- លោក **សាយ ពុទ្ធា** | តំណាងនិយោជិតរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | នីតិសមាជិក។ |

**មាត្រា២..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែ៣ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Cambodian Agricultural Research and Development Institute



Cambodian Agricultural Research and Development Institute